# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៦-៣-២០០៥ | -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៣៧ ស្ដីពីការប្រោសព្រះរាជទានចំពោះ ឯកឧត្ដម **ថ្លៃ សុខា** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** | ៣៤៨៥ |
| ២១-៥-២០០៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២២៨ ស្ដីពីការតែងតាំងលោក **កែវ សំអឿន** ជាឧបការី សម្ដេចក្រុមព្រះ **នរោត្ដម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នីតិកាលទី ៣ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ទទួលបន្ទុកកិច្ចការធម្មការ និង សាសនា | ៣៤៨៦ |
| ២៩-៥-២០០៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២៣០ ស្ដីពីរូបសញ្ញាបច្ចេកទេស សញ្ញាស័ក្ដិ និងឯកសណ្ឋានមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម | ៣៤៨៧ |
| ២៩-៥-២០០៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២៣១ ស្ដីពីការតម្លើងឋានន្តរស័ក្ដិថ្នាក់ **ឧត្ដមសេនីយ៍ទោ** នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៣ រូប | ៣៥០៤ |
| ២៩-៥-២០០៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២៣៣ ស្ដីពីការបញ្ឈប់មុខងារឯកឧត្ដម **សម ជារាដ្ឋ** ពីទីប្រឹក្សាផ្ទាល់សម្ដេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា | ៣៥០៥ |
| ២៩-៥-២០០៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២៣៦ ស្ដីពីការ តែងតាំងឯកឧត្ដម **យ៉ៅ ចន្ទរិទ្ធ** ជាអគ្គរាជទូតគោចរ ទទួលបន្ទុកកិច្ចការប្រ្ញង់កូហ្វូនី ប្រចាំសាធារណរដ្ឋបារាំង ដោយមិនទទួលប្រាក់បៀវត្ស | ៣៥០៦ |
| ២៩-៥-២០០៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២៣៧ ស្ដីពីការ ផ្លាស់ឯកឧត្ដម **សរ សម្បត្តិ** បច្ចុប្បន្នជាតំណាងអចិន្ត្រៃយ៍រង នៃស្ថានបេសកកម្ម អចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ វិលចូលប្រទេសវិញ ដោយសាមីខ្លួនមានកំហុសនយោបាយធ្ងន់ធ្ងរ | ៣៥០៧ |
| ២៩-៥-២០០៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២៣៨ ស្ដីពីការតែងតាំងឯកឧត្ដម **ស៊ា កុសល** បច្ចុប្បន្នជាអគ្គទីប្រឹក្សានៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសហរដ្ឋអាមេរិក ជាតំណាងអចិន្ត្រៃយ៍រង នៃស្ថានបេសកកម្ម អចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ ដោយមានឋានៈជាអគ្គរាជទូត | ៣៥០៨ |

២៩-៥-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២៤០ ស្តីពីការបង្កើតសហគមន៍នេសាទ ៣៥០៩

២៩-៥-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២៤១ ស្តីពីការតែងតាំងឯកឧត្តម **ឡៅ ថេន** ជាទីប្រឹក្សាផ្ទាល់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នីតិកាលទី ៣ មានឋានៈស្មើ **រដ្ឋលេខាធិការ** ៣៥១១

២៩-៥-២០០៥ -ព្រះរាជក្រឹត្យនស/រកត/០៥០៥/២៤២ស្តីពីការតែងតាំងឯកឧត្តម **សែម សុវណ្ណជេត** ជាទីប្រឹក្សាផ្ទាល់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នីតិកាលទី ៣ មានឋានៈស្មើ **រដ្ឋលេខាធិការ** ៣៥១២

០១-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៤៣ ស្តីពីការតែងតាំងឯកឧត្តម **សូត្រ សម្បត្តិ** ជាទីប្រឹក្សារបស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារពាណិជ្ជកម្មក្នុង និងក្រៅប្រទេស មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ៣៥១៣

០១-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៤៩ ស្តីពីការតែងតាំងឯកឧត្តម **ញឹម ខេមរា** ជាអគ្គលេខាធិការរង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានឋានៈស្មើ **អគ្គនាយក** ៣៥១៤

០១-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៥០ ស្តីពីតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៣ រូប ៣៥១៥

០១-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៥១ ស្តីពីតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៤ រូប ៣៥១៥

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

០១-៦-២០០៥ -អនុក្រឹត្យលេខ ៧៤ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៣៥១៧

០១-៦-២០០៥ -អនុក្រឹត្យលេខ ៧៥ អនក្រ.បក ស្តីពីការបង្កើតក្រុមប្រឹក្សានីតិកម្ម និងនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ចំណុះក្រសួងមហាផ្ទៃ ៣៥១៩

០២-៦-២០០៥ -អនុក្រឹត្យលេខ ៧៦ អនក្រ.បក ស្តីពី ការកែសម្រួលមាត្រា ៥ នៃអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើតអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ៣៥២៣

០៦-៦-២០០៥ -អនុក្រឹត្យលេខ ៧៧ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរផ្លូវគោក ៣៥២៥

០៦-៦-២០០៥ -អនុក្រឹត្យលេខ ៧៨ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៣៥៣១
០៨-៦-២០០៥ -អនុក្រឹត្យលេខ ៧៩ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៣៥៣៣
០២-៦-២០០៥ -អនុក្រឹត្យលេខ ៤៧២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៣៥
០២-៦-២០០៥ -អនុក្រឹត្យលេខ ៤៧៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៣៦
០២-៦-២០០៥ -អនុក្រឹត្យលេខ ៤៧៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៣៨
០២-៦-២០០៥ -អនុក្រឹត្យលេខ ៤៧៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៤០
០២-៦-២០០៥ -អនុក្រឹត្យលេខ ៤៧៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៤១
០៣-៦-២០០៥ -អនុក្រឹត្យលេខ ៤៧៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៤៣
០៣-៦-២០០៥ -អនុក្រឹត្យលេខ ៤៧៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៤៦
០៣-៦-២០០៥ -អនុក្រឹត្យលេខ ៤៧៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៤៨
០៣-៦-២០០៥ -អនុក្រឹត្យលេខ ៤៨០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៤៩
០៣-៦-២០០៥ -អនុក្រឹត្យលេខ ៤៨១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៥០
០៣-៦-២០០៥ -អនុក្រឹត្យលេខ ៤៨២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៥២
០៣-៦-២០០៥ -អនុក្រឹត្យលេខ ៤៨៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៥៣
០៣-៦-២០០៥ -អនុក្រឹត្យលេខ ៤៨៤ អនក្រ.តត ស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ៣៥៥៤
០៣-៦-២០០៥ -អនុក្រឹត្យលេខ ៤៨៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៥៥
០៣-៦-២០០៥ -អនុក្រឹត្យលេខ ៤៨៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៥៧
០៣-៦-២០០៥ -អនុក្រឹត្យលេខ ៤៨៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៥៨
០៣-៦-២០០៥ -អនុក្រឹត្យលេខ ៤៨៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៥៥៩
០៣-៦-២០០៥ -អនុក្រឹត្យលេខ ៤៨៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៣៥៦០
០៣-៦-២០០៥ -អនុក្រឹត្យលេខ ៤៩០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៥៦១
០៦-៦-២០០៥ -អនុក្រឹត្យលេខ ៤៩១ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៣៥៦២
០៨-៦-២០០៥ -អនុក្រឹត្យលេខ ៤៩២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៥៦៤
០៨-៦-២០០៥ -អនុក្រឹត្យលេខ ៤៩៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៥៦៥
០៨-៦-២០០៥ -អនុក្រឹត្យលេខ ៤៩៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៦៦

០៨-៦-២០០៥ -អនុក្រឹត្យលេខ ៤៩៥ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៥៦៧

០៨-៦-២០០៥ -អនុក្រឹត្យលេខ ៤៩៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៦៨

០៨-៦-២០០៥ -អនុក្រឹត្យលេខ ៤៩៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៧០

០៨-៦-២០០៥ -អនុក្រឹត្យលេខ ៤៩៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៧២

០៨-៦-២០០៥ -អនុក្រឹត្យលេខ ៤៩៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៧៣

## ២_សេចក្តីសំរេច

០២-៦-២០០៥ -សេចក្តីសំរេចលេខ ១៤ សសរ ស្តីពីការបង្កើតក្រុមការងារសម្រាប់បំភ្លឺទៅនឹងមតិជំទាស់ជាមួយនយោបាយដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ៣៥៧៤

## III_ការងារបណ្តាក្រសួង

## ១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៣-៦-២០០៥ -ប្រកាសលេខ ២៧០ សហវ.ប្រក ស្តីពីការប្រមូលលើពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៥ ៣៥៧៦

០៣-៦-២០០៥ -សេចក្តីសំរេចលេខ ០០១ សសរ. សហវ.ពដ ស្តីពីការបង្កើតអនុគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ៣៥៨៦

## ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

០៦-៦-២០០៥ -ប្រកាសលេខ ៤០៤ ឧរថ. អថ.ប្រក ស្តីពី ការកែសំរួលគោលនយោបាយឧបត្ថម្ភ សំរាប់បំពេញខាតឱ្យអតិថិជនប្រើប្រាស់អគ្គិសនីប្រភេទលំនៅដ្ឋាន នៅរាជធានីភ្នំពេញនិងខេត្តកណ្តាល ៣៥៩៤

## ៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៥-៥-២០០៥ -លិខិតលេខ ១១៨២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អ.អិល.អេស អ៊ីមផត អិចផត** ៣៥៩៧

២៥-៥-២០០៥ -លិខិតលេខ ១១៨៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អេស.ទី.អេស** ៣៥៩៩

២៥-៥-២០០៥ -លិខិតលេខ ១១៨៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **រ៉ាស្មី លេប៉រ ស៊ីបផ្លាយ** ៣៦០១

២៥-៥-២០០៥ -លិខិតលេខ ១១៨៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ៊ីម៉ាប់** ៣៦០៣

២៥-៥-២០០៥ -លិខិតលេខ ១១៨៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ម៉ាស្ទើរ ឡែន** ៣៦០៥

២៥-៥-២០០៥ -លិខិតលេខ ១១៩០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ធី.អេ.ខេ ឌីវេឡុបមេន** ៣៦០៧

២៥-៥-២០០៥ -លិខិតលេខ ១១៩២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ត្រេនឃៃរ ខូ អិលធីឌី** ៣៦០៩

២៥-៥-២០០៥ -លិខិតលេខ ១១៩៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ថែម លេនម៉ាក អ៊ិនវេសមេន** ៣៦១១

២៥-៥-២០០៥ -លិខិតលេខ ១១៩៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេស៊ាន ហូម ប្រូដាក & សឺវីស** ៣៦១៣

២៥-៥-២០០៥ -លិខិតលេខ ១១៩៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេ អិល អេស ខូ អិលធីឌី** ៣៦១៥

២៥-៥-២០០៥ -លិខិតលេខ ១១៩៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ម៉ូដឺន ប្លាស្ទិក & ផាកខេជីង (ខេមបូឌា)** ៣៦១៧

២៥-៥-២០០៥ -លិខិតលេខ ១១៩៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អិល ឌី គ្លូប៊ល** ៣៦១៨

២៥-៥-២០០៥ -លិខិតលេខ ១២០១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេស៊ាន ធូ អ៊ិនវេសមេន** ៣៦២០

២៥-៥-២០០៥ -លិខិតលេខ ១២២០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**សុខុម ខូ អិលធីឌី** ៣៦២២

២៥-៥-២០០៥ -លិខិតលេខ ១២០៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ៊ី-ស្មាត អ៊ិនធើណេសិនណាល** ៣៦២៤

២៥-៥-២០០៥ -លិខិតលេខ ១២០៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ប៊ីសវីស** ៣៦២៦

២៥-៥-២០០៥ -លិខិតលេខ ១២០៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឌីស៊ី អ៊ិនធីគ្រេធីត (ខេមបូឌា) ភីធីអ៊ី អិលធីឌី** ៣៦២៨

២៧-៥-២០០៥ -លិខិតលេខ ១២០៩ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**សហាគ្រិន ខេមបូឌាន អាមើរិខិន** ៣៦៣០

២៧-៥-២០០៥ -លិខិតលេខ ១២១០ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស៊ីន_តូអិ ត្រេឌីង** ៣៦៣២

២៧-៥-២០០៥ -លិខិតលេខ ១២១១ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឆាយណា ភ្នំពេញ ហ្គោល ម៉ាញនីង** ៣៦៣៤

២៧-៥-២០០៥ -លិខិតលេខ ១២១២ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ & ឌី ត្រាឌើរ** ៣៦៣៦

២៧-៥-២០០៥ -លិខិតលេខ ១២១៤ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ៊ែម @ រីច** ៣៦៣៨

២៧-៥-២០០៥ -លិខិតលេខ ១២១៥ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ទេង ថៃ ទេង អិចប្រេស** ៣៦៤០

២៧-៥-២០០៥ -លិខិតលេខ ១២១៦ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**គូ ហ៊ុនដា អ៊ីមផត អិចផត** ៣៦៤២

២៧-៥-២០០៥ -លិខិតលេខ ១២២៦ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេស៊ាន ផាប់ប្លិក រីលេសិន អេឃើជីមី (ខេមបូឌា)** ៣៦៤៤

២៧-៥-២០០៥ -លិខិតលេខ ១២២៧ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស៊ីណាន ត្រេឌីង** ៣៦៤៦

២៧-៥-២០០៥ -លិខិតលេខ ១២២៨ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**(ខេមបូឌា) ស្ទេសិនរី ផេភើរ អេន ព្រីនធីង ម៉ាស៊ីន** ៣៦៤៨

២៧-៥-២០០៥ -លិខិតលេខ ១២២៩ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**មេក អ៊ិនធើធេនមេន ក្លឹប អិលធីឌី** ៣៦៥០

នស/រកត/០៣០៥/១៣៧

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម ឡាំ សុខា

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៥០៣.១៤០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០០៥

លេខ ៖ ៦១៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/២២៨

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងលោក **តែង សំអឿន** ជាឧបការី សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ទទួលបន្ទុកកិច្ចការធម្មការ និង សាសនា ។

មាត្រា ២ : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសម្រេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

តារា.០៥០៥.២៤៣

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៥*

លេខ ៦២៧ ច.ល
ដើម្បីចម្លងចែកចាយ
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សៅ ឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/២៣០

## ស្តីពី

## រូបសញ្ញាបច្ចេកទេស សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥២ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៥

# គ្រាស់បង្គាប់

## ជំពូក ទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .–**

ត្រូវបានបង្កើតរូបសញ្ញាបច្ចេកទេស សញ្ញាស័ក្តិ និងឯកសណ្ឋានសម្រាប់សំគាល់មន្ត្រីរាជការ ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ដែលបំរើការងារនៅតាមក្រសួង ស្ថាប័ននានា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២ .–**

សញ្ញាស័ក្តិ និងឯកសណ្ឋាននេះ សម្រាប់ប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗ ។

## ជំពូក ទី ២

## រូបសញ្ញាបច្ចេកទេស

**មាត្រា ៣ .–**

រូបសញ្ញាបច្ចេកទេសត្រូវបានកំណត់ដូចតទៅ ÷

- -មានរាងពងក្រពើ លំអដោយពណ៌មាសសម្រាប់ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងពណ៌ប្រាក់សម្រាប់ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម
- -ទទឹងប្រវែង ១ ភាគ ២ នៃបណ្តោយ
- -នៅចំកណ្តាល មានរូបព្រះវិស្ណុឈរលើបល្ល័ង្កលំអដោយក្បាច់ត្របកផ្កាឈូក ដែលមានព្រះហស្តបួន ។ ព្រះហស្តពីរខាងលើ ខាងឆ្វេងកាន់ខ្សងស័ង្ខ ខាងស្តាំកាន់កងចក្រ ព្រះហស្តពីរទៀតខាងក្រោម ខាងឆ្វេងកាន់ដំបងបញ្ឈរទៅក្រោម ឯខាងស្តាំកាន់ដុំមូល
- -នៅអមសងខាងព្រះវិស្ណុ មាននាគមួយគូ នៅពីលើក្បាលនាគនីមួយៗ មានក្បាច់ព័ទ្ធទៅលើប្រសព្វមុខគ្នាជាកំពូលរាងជ្រលម ។

រូបសញ្ញាបច្ចេកទេសនេះ សម្រាប់ដាក់នៅលើស័ក្តិស្មា ស័ក្តិចុងកអាវ និងដាក់នៅលើស័ក្តិខ្ចាស់លើអាវ បុរស ឬលើក្រមាពានារបស់នារី នៃមន្ត្រីក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ។

រូបសញ្ញាបច្ចេកទេសនេះ មានរូបភាពដូចក្នុងឧបសម្ព័ន្ធទី ១ ។

## ជំពូក ទី ៣

## សញ្ញាស័ក្តិ

មាត្រា ៤ –

សញ្ញាស័ក្តិមន្ត្រីក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងមន្ត្រីក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យមត្រូវកំណត់ដូចតទៅ ÷

## ក_ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់

### ១_អំពីស័ក្តិស្មា

ស័ក្តិស្មាមានផ្ទៃកម្ទីពណ៌បៃតងចាស់ រចនាតុបតែងដោយក្បាច់ភ្ញីវល្លិប្រភេទស្លឹកព្នៅពីរមែកពណ៌មាសដាក់ខ្វែងគ្នា ហើយនៅពីលើក្បាច់ទាំងពីរនោះ មានរូបសញ្ញាបច្ចេកទេសពណ៌មាស និងនៅពីខាងលើរូបសញ្ញាបច្ចេកទេស មានឡេវរូបព្រះសង្ហារពណ៌មាសមួយ ។ បន្ទាប់មកមានក្បាច់ផ្កាដូងមួយខ្សែពណ៌មាសព័ទ្ធជុំវិញក្នុងឋាន ។ ផ្ទៃខាងក្រៅនៃក្បាច់ផ្កាដូងនេះមានខ្សែពួរវេញព័ទ្ធជុំវិញពណ៌មាស បីខ្សែសម្រាប់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ពីរខ្សែសម្រាប់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ និងមួយខ្សែសម្រាប់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ។

ខ្នាតស័ក្តិស្មាត្រូវបានកំណត់ដូចខាងក្រោម ÷

| | | |
|---|---|---|
| -បាតក្រោម | ប្រវែង ៦ | សង្ទីម៉ែត្រ |
| -ទទឹងមុខកាត់ផ្នែកខាងលើ | ប្រវែង ៤.៤០ | សង្ទីម៉ែត្រ |
| -បណ្តោយពីលើដល់បាតក្រោម | ប្រវែង ១៣ | សង្ទីម៉ែត្រ ។ |

### ២_អំពីស័ក្តិចុងកអាវខាងសងខាង

ស័ក្តិចុងកអាវមានផ្ទៃកម្ទីពណ៌បៃតងចាស់ រចនាតុបតែងដោយក្បាច់ភ្ញីវល្លិប្រភេទស្លឹកព្នៅពីរមែកពណ៌មាសដាក់ខ្វែងគ្នា ហើយមានរូបសញ្ញាបច្ចេកទេសពណ៌មាសនៅពីខាងមុខ។ បន្ទាប់មកមានក្បាច់ផ្កាដូងពណ៌មាសមួយខ្សែ និងមានខ្សែពួរវេញពណ៌មាសនៅផ្នែកខាងលើភ្ជាប់ជាមួយចំហៀងខាងមុខ បីខ្សែសម្រាប់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ពីរខ្សែសម្រាប់សំគាល់ឋានន្តស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ និងមួយខ្សែសម្រាប់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ។

ខ្នាតស័ក្តិចុងកអាវត្រូវបានកំណត់ដូចខាងក្រោម ÷

-មានរាងជាប្រលេឡូក្រាម

| | | |
|---|---|---|
| -បណ្តោយ | ប្រវែង ៩ | សង្ទីម៉ែត្រ |
| -ទទឹង | ប្រវែង ៣.៨ | សង្ទីម៉ែត្រ ។ |

### ៣_អំពីស័ក្តិចុងដៃអាវខាងសងខាង

ស័ក្តិចុងដៃអាវមានផ្ទៃកម្ទីពណ៌បៃតងចាស់ រចនាតុបតែងដោយក្បាច់ភ្ញីវល្លិប្រភេទស្លឹកព្នៅដប់មែកពណ៌មាស និងមានក្បាច់ផ្កាដូងពណ៌មាសមួយខ្សែនៅខាងលើ និងជាយផ្នែកចំហៀងសងខាង ។ ផ្ទៃខាងក្រៅ នៃក្បាច់ផ្កាដូងនេះ មានខ្សែពួរវេញពណ៌មាសនៅផ្នែកខាងលើ និងផ្នែកចំហៀងទាំងសងខាង បីខ្សែសម្រាប់សំគាល់

ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ពីរខ្សែសម្រាប់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ និងមួយខ្សែសម្រាប់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ។ នៅបាតក្រោមបង្អស់ នៃសញ្ញាចុងដៃអាវ មានខ្សែពួរវេញពណ៌មាសមួយខ្សែ ។

ខ្នាតនៃស័ក្តិចុងដៃអាវទាំងសងខាង ត្រូវបានកំណត់ដូចខាងក្រោម ÷

-មានរាងបួនជ្រុងទ្រវែង

-បណ្តោយ ប្រវែង ៣២ សង្ទីម៉ែត្រ

-ទទឹង ប្រវែង ៩ សង្ទីម៉ែត្រ ។

រូបសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវទាំងសងខាងសម្រាប់មន្ត្រី ÷

-ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស មានដូចក្នុងឧបសម្ព័ន្ធទី ២

-ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ មានដូចក្នុងឧបសម្ព័ន្ធទី ៣

-ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ មានដូចក្នុងឧបសម្ព័ន្ធទី ៤ នៃព្រះរាជក្រឹត្យនេះ ។

ដោយឡែកស័ក្តិស្មា ស័ក្តិចុងកអាវ និងស័ក្តិចុងដៃអាវទាំងសងខាងសម្រាប់នារី មានទំហំដូចខាងក្រោមនេះ ÷

-ចំពោះស័ក្តិស្មា អាចមានទំហំ ៨០% ៨៥% ៩០% នៃទំហំស័ក្តិស្មារបស់បុរសអាស្រ័យលើមាឌរបស់នារី

-ចំពោះចុងកអាវមានទំហំទទឹង ៣ សង្ទីម៉ែត្រ ទៅ ៣.៥ សង្ទីម៉ែត្រ អាស្រ័យលើកំពស់ករបស់នារី

-ចំពោះស័ក្តិចុងដៃអាវ អាចមានទំហំទទឹងស្មើនឹង ៧០% ទៅ ៧៥% នៃទំហំទទឹងស័ក្តិចុងដៃអាវបុរស អាស្រ័យលើមាឌរបស់នារី ។

## ៤.អំពីស័ក្តិខ្ទាស់លើអាវសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់

ស័ក្តិខ្ទាស់លើអាវសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ មានរាងពងក្រពើ និងកំពូលរាងជ្រលមកំពស់ ៧.៥ សង្ទីម៉ែត្រ ទទឹង ៤.៥ សង្ទីម៉ែត្រ ។ ផ្នែកខាងក្នុងមានរូបសញ្ញាបច្ចេកទេសពណ៌មាស បន្ទាប់មកមានក្បាច់ផ្កាដូងពណ៌មាសមួយព័ទ្ធអមផង ។ ផ្នែកខាងក្រោមមានខ្សែពួរវេញព័ទ្ធអមពណ៌មាស បីខ្សែសម្រាប់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ពីរខ្សែសម្រាប់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ និងមួយខ្សែសម្រាប់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ។

ស័ក្តិខ្ទាស់លើអាវនេះ សម្រាប់ខ្ទាស់លើអាវនៅពេលបំពេញការងារ ។ ស័ក្តិនេះក៏សម្រាប់ខ្ទាស់ក្រមាពានានារី ក្នុងឯកសណ្ឋានប្រពៃណីដែរ ។

រូបគំនូរស័ក្តិខ្ទាស់លើអាវ និងលើក្រមាពានាសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដូចមានក្នុងឧបសម្ព័ន្ធទី ៥ នៃព្រះរាជក្រឹត្យនេះ ។

**ខ-ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម**

សញ្ញាស័ក្តិសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម មានសណ្ឋានរូបភាព និងមានការកំណត់បែងចែកទៅតាមប្រភេទឋានន្តរស័ក្តិដូចសញ្ញាស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដែរ ប៉ុន្តែខុសគ្នាត្រង់សញ្ញាស័ក្តិក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យមមានពណ៌ប្រាក់ ។

រូបសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវសម្រាប់ ÷

-ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែពិសេស មានដូចក្នុងឧបសម្ព័ន្ធទី ៦

-ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ មានដូចក្នុងឧបសម្ព័ន្ធទី ៧ និង

-ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យម មានដូចក្នុងឧបសម្ព័ន្ធទី ៨ នៃព្រះរាជក្រឹត្យនេះ ។

## ជំពូក ទី ៤

## ប្រភេទឯកសណ្ឋាន និង ការប្រើប្រាស់

**មាត្រា ៥ .-**

ប្រភេទឯកសណ្ឋានសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ត្រូវបានកំណត់ដូចខាងក្រោម ÷

**ក-ឯកសណ្ឋានផ្លូវការ**

**១-ចំពោះបុរស**

អាវកុដពណ៌ស កត្រង់ ដៃវែង កាត់រាងអាវធំ មានបន្ទះលើស្មាសម្រាប់ដាក់ស័ក្តិ និងគ្មានផែកខ្នង ។ អាវនេះមានហោប៉ៅចំនួនបួន គឺហោប៉ៅខាងលើពីរដេរបង្កប់ មានគំរបរាងបួនជ្រុងទ្រវែងមានតែមរាងមូល ហោប៉ៅខាងក្រោមពីរដេរបង្កប់ មានគំរបរាងបួនជ្រុងទ្រវែង មានតែមរាងមូល ហើយនៅលើគំរបហោប៉ៅទាំងបួននោះ មានឡេវរូបព្រះសង្ហារពណ៌មាស ឬ ពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ ។ អាវកុដពណ៌សនេះ មានឡេវរូបព្រះសង្ហារចំនួន ៧ ពណ៌មាស ឬ ពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ ។

ខោកាគីជើងវែង ស្បែកជើងឃ្មុបពណ៌ខ្មៅចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ។

**២-ចំពោះស្ត្រី**

អាវជីបរាងពណ៌ស ដោយប្រើសាច់ក្រណាត់ដូចឈុតអាវរបស់បុរស កតាំង ដៃវែង ត្រឹមភ្នែកគោលដៃ គ្មានផែកខ្នង ។ បិទឡេវមុខ ដាក់ឡេវរូបព្រះសង្ហារចំនួន ៥ ពណ៌មាស ឬ ពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ ។ ចុងកអាវមានស័ក្តិ លើស្មាមានបន្ទះសម្រាប់ដាក់ស័ក្តិ គ្មានហោប៉ៅ ។

សំពត់សំឡុយពណ៌កាគី មានសំរុងលើភ្នែកគោលនៃស្មងជើង ប្រវែងពី ១០ ទៅ ១៥ សង្ទីម៉ែត្រ អនុលោម ទៅតាមមាឌ និងកំពស់របស់នារី ។

ស្បែកជើងឃ្មុបមុខ ឃ្មុបក្រោយ មានកែង ពណ៌សសម្រាប់ពេលព្រឹក ពណ៌ខ្មៅសម្រាប់ពេលល្ងាច ។ រូបគំនូរឯកសណ្ឋានផ្លូវការសម្រាប់បុរស និងស្ត្រី នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងមន្ត្រីក្របខ័ណ្ឌមន្ត្រី

បច្ចេកទេសមធ្យម មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៩ នៃព្រះរាជក្រឹត្យនេះ ។

ខ.ឯកសណ្ឋានប្រពៃណីជាតិ

១.ចំពោះបុរស

-អាវកុដពណ៌ស កត្រង់ ដៃវែងកាត់រាងអាវធំ មានបន្ទះលើស្មាសម្រាប់ដាក់ស័ក្តិ និងគ្មានផែកខ្នង អាវនេះ មានហោប៉ៅចំនួនបួន គឺហោប៉ៅខាងលើពីរដេរបង្កប់ មានគំរបរាងបួនជ្រុងទ្រវែងមានគែមរាងមូល ហោប៉ៅខាងក្រោមពីរដេរបង្កប់ មានគំរបរាងបួនជ្រុងទ្រវែងមានគែមរាងមូល ហើយនៅលើគំរបហោប៉ៅទាំងបួននេះ មានឡេវរូបព្រះសង្ហារពណ៌មាស ឬ ពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ

-អាវកុដពណ៌សនេះ មានឡេវរូបព្រះសង្ហារចំនួន ៧ ពណ៌មាស ឬ ពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ

-សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ

-ស្បែកជើងឃ្លុបពណ៌ខ្មៅ កខ្លី មានចងខ្សែ ស្រោមជើងពណ៌ខ្មៅដល់ក្បាលជង្គង់ ។

២.ចំពោះស្ត្រី

-អាវជីបរាងពណ៌ស មានកមូល ដៃវែង រួតខ្លួនបន្តិច នៅចុងអាវមានស័ក្តិ និងមានឡេវបញ្ឆោត ៣ រូបព្រះសង្ហារពណ៌មាស ឬ ពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ

-សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ

-ពានាក្រមាតាមពណ៌សំពត់ ឬ ពានាក្រមាពណ៌ស៊ីន្ទូន តាមពិធីការកំណត់

-នៅលើក្រមាពានាផ្នែកខាងឆ្វេងនៃដើមទ្រូង មានស័ក្តិខ្ចាស់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ឬ មធ្យម

-ស្បែកជើងឃ្លុបមុខ ឃ្លុបក្រោយ ពណ៌សសម្រាប់ពេលព្រឹក ពណ៌ខ្មៅសម្រាប់ពេលល្ងាច

-កាបូបយួរដៃពណ៌ស ឬ ពណ៌ខ្មៅ (មិនអោយស្ពាយទេ) ស្របតាមការប្រើស្បែកជើងពណ៌ស ឬ ពណ៌ខ្មៅ ។

រូបគំនូរឯកសណ្ឋានប្រពៃណីជាតិសម្រាប់បុរស និងស្ត្រី នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ មានគំរូដូចក្នុងឧបសម្ព័ន្ធទី ១០ ។

**មាត្រា ៦ .–**

ការប្រើប្រាស់ឯកសណ្ឋានសម្រាប់មន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងមន្ត្រីបច្ចេកទេសមធ្យម ត្រូវបានកំណត់ដូចខាងក្រោម ÷

-ឯកសណ្ឋានផ្លូវការសម្រាប់ប្រើប្រាស់ក្នុងឱកាសទិវាបុណ្យប្រពៃណីជាតិ និងពិធីការផ្សេងៗ

-ចំពោះឯកសណ្ឋានប្រពៃណីជាតិសម្រាប់ប្រើប្រាស់ក្នុងទិវាបុណ្យប្រពៃណី និងសាសនាដែលប្រារព្ធធ្វើឡើងនៅក្នុងព្រះបរមរាជវាំង ក្នុងវត្តអារាម ឬ កន្លែងផ្សេងៗ ត្រូវបានកំណត់អោយប្រើឯកសណ្ឋាននេះតែមន្ត្រីក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ។

## ជំពូក ទី ៥
## របបកំណត់ឯកសណ្ឋាន និង សញ្ញាស័ក្តិ

**មាត្រា ៧ .—**

ត្រូវបានផ្តល់ជូនដល់មន្ត្រីម្នាក់ៗ នូវឯកសណ្ឋានផ្លូវការមួយសម្រាប់ និងឯកសណ្ឋានប្រពៃណីជាតិមួយសម្រាប់ ព្រមទាំងសញ្ញាស័ក្តិ និងសម្ភារៈផ្សេងៗទៀតដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ សម្រាប់រយៈពេលបីឆ្នាំម្តង ។

## ជំពូក ទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ៨ .—**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩ .—**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.០៥០៥.៧៤៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

លេខ ២១០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សាខឺ តាន់**



/14



ឧបសម្ព័ន្ធទី ២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៣០
ចុះថ្ងៃទី ២៩ ឧសភា ឆ្នាំ ២០០៥
ស្តីពីរូបសញ្ញាបច្ចេកទេស សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រី នៃក្របខ័ណ្ឌមន្ត្រី
បច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌបច្ចេកទេសមធ្យម

# សញ្ញាស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស (ពណ៌មាស)



ស័ក្តិកអាវ



ស័ក្តិប៉ាន់ស្មា



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០៤/២៣០
ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៤
...រូបសញ្ញាបច្ចេកទេស សញ្ញាស័ក្តិ និងកែសញ្ញាអាត្រ្នី ...
...បច្ចេកទេសជាន់ខ្ពស់ និងគ្រប់ខ្សែបច្ចេកទេសមធ្យម

# សញ្ញាស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ជើងខ្សែ (ពណ៌មាស)



សំក្តិកអាវ



សំក្តិប៉ានស្មា



សំក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៣០
ចុះថ្ងៃទី ២៩ ឧសភា ឆ្នាំ ២០០៥
ស្តីពីឯកសណ្ឋានមន្ត្រីបច្ចេកទេស សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រី នៃក្របខ័ណ្ឌមន្ត្រី
បច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌបច្ចេកទេសមធ្យម

## សញ្ញាស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ (ពណ៌មាស)



ស័ក្តិកអាវ



ស័ក្តិប៉ាន់ស្មា



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៨ នស/រកត/០៥០៥/២៣០
ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥
ស្តីពីរូបសញ្ញាបច្ចេកទេស សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រី នៃក្របខ័ណ្ឌមន្ត្រី
បច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌបច្ចេកទេសមធ្យម

## ស័ក្តិខ្ទាស់លើអាវសម្រាប់មន្ត្រី
## នៃក្របខ័ណ្ឌ មន្ត្រីបច្ចេកទេសជាន់ខ្ពស់



សម្រាប់ឋានន្តរស័ក្តិ
មន្ត្រីបច្ចេកទេសជាន់ខ្ពស់



សម្រាប់ឋានន្តរស័ក្តិ
មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ



សម្រាប់ឋានន្តរស័ក្តិ
មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស

ឧបសម្ព័ន្ធទី ៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៣០

ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥

ស្តីពីរូបសញ្ញាបច្ចេកទេស សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រី នៃក្របខ័ណ្ឌមន្ត្រី

បច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម

# សញ្ញាស័ក្តិមន្ត្រីបច្ចេកទេសមធ្យមជើងខ្សែពិសេស (ពណ៌ប្រាក់)



ស័ក្តិកអាវ



ស័ក្តិប៉ានស្មា



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៣០
ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥
ស្តីពីរូបសញ្ញាបច្ចេកទេស សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌបច្ចេកទេសមធ្យម

## សញ្ញាស័ក្តិមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ (ពណ៌ប្រាក់)



ស័ក្តិកអាវ



ស័ក្តិប៉ានស្មា



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៨ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៣០
ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០០៥
ស្តីពីរូបសញ្ញាបច្ចេកទេស សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រី នៃក្របខ័ណ្ឌមន្ត្រី
បច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌបច្ចេកទេសមធ្យម

## សញ្ញាស័ក្តិមន្ត្រីបច្ចេកទេសមធ្យម (ពណ៌ប្រាក់)



ស័ក្តិករអាវ



ស័ក្តិប៉ាន់ស្មា



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៩ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៣០
ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៥
ស្តីពីរូបសញ្ញាបច្ចេកទេស សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌបច្ចេកទេសមធ្យម

## ឯកសណ្ឋានផ្លូវការ សម្រាប់បុរស និង ស្ត្រី



ឧបសម្ព័ន្ធទី ១០ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៣០
ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០០៥
ស្ដីពីរូបសញ្ញាបច្ចេកទេស សញ្ញាស័ក្ដិ និងឯកសណ្ឋានមន្ត្រី នៃក្របខ័ណ្ឌមន្ត្រី
បច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌបច្ចេកទេសមធ្យម

## ឯកសណ្ឋានប្រពៃណី សម្រាប់បុរស និង ស្ត្រី



# ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/២៣១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រ្តីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ÷

១-ឧត្តមសេនីយ៍ត្រី ស៊ូ **សុវណ្ណមុនី** អត្តលេខ ០០០៧៨៧

២-ឧត្តមសេនីយ៍ត្រី ទួន **សំអាន** អត្តលេខ ០០២១៩៦

៣-ឧត្តមសេនីយ៍ត្រី ប៉ែន **វ៉ា** អត្តលេខ ០០០៨០៣

**មាត្រា២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣កស-០៥០៥-២៤៦

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០០៥*

លេខ: ៦៣១ ច.ល
ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

2/2

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/២៣៣

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានបញ្ឈប់មុខងារឯកឧត្តម សម ជាភរដ្ឋ ពីទីប្រឹក្សាផ្ទាល់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ។

**មាត្រា ២:** ប្រធានព្រឹទ្ធសភា និង នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ ២១៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

៣រស.០៥០៥.២៤៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៥

សុខ តាន់

នស/រកត/០៥០៥/២៣៦

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម យ៉ៅ ចន្ទរិទ្ធ ជាអគ្គរាជទូតគោចរ ទទួលបន្ទុកកិច្ចការហ្រ្វង់កូហ្វូនី ប្រចាំសាធារណរដ្ឋបារាំង ដោយមិនទទួលប្រាក់បៀវត្ស។

**មាត្រា ២ :** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣/ល.០៥០៥.២៩១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០០៥

លេខ : ២១៧០៥ ច.ល
**ដើម្បីចម្លងចែកជូន**
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង ឌាន់**

Created by Chhor Phaly

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/២៣៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤/ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្លាស់ឯកឧត្តម **សរ សម្បត្តិ** បច្ចុប្បន្នជាតំណាងអចិន្ត្រៃយ៍រង នៃស្ថានបេសកកម្មអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ វិលចូលប្រទេសវិញ ដោយសាមីខ្លួនមានកំហុសនយោបាយធ្ងន់ធ្ងរ ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ ៦២៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សាឌី តាន់

៣៤.០៥០៥.២៥២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/២៣៨

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ត្រពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤/ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម ស៊ា កុសល បច្ចុប្បន្នជាអគ្គទីប្រឹក្សានៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសហរដ្ឋអាមេរិក ជាតំណាងអចិន្ត្រៃយ៍រង នៃស្ថានបេសកកម្មអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ [illegible]យ មានឋានៈជាអគ្គរាជទូត ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ ៖ ២៣[illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០[illegible]
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] តាន់

៣រស.០៥០៥.៧៥៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៥

3/3

នស/រកត/០៥០៥/២៤០

# ព្រះរាជក្រឹត្យ

## ស្តីពី

## ការបង្កើតសហគមន៍នេសាទ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៥

## ត្រាស់បង្គាប់

**មាត្រា ១.-**

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិរួមគ្នាបង្កើតសហគមន៍នេសាទនៅតាមមូលដ្ឋានរបស់ខ្លួន ដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត និងមានគំនិតផ្តួចផ្តើមបង្កើនជីវភាពរស់នៅរបស់ខ្លួន តាមរយៈការប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាព ដើម្បីរួមចំណែកលើកតម្កើងសេដ្ឋកិច្ច សង្គមកិច្ច និងកាត់បន្ថយភាពក្រីក្រ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសមត្ថកិច្ចទូទៅលើការគ្រប់គ្រងសហគមន៍នេសាទ ។

2/3

**មាត្រា ២.–**

សហគមន៍នេសាទត្រូវមានលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រង ផែនទីកន្លែងនេសាទសហគមន៍របស់ខ្លួន និងកិច្ចព្រមព្រៀងដែលមានការទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ច ។

**មាត្រា ៣.–**

សហគមន៍នេសាទដែលមានដែននេសាទជាប់គ្នា អាចចូលរួមជាមួយគ្នាដោយបង្កើតជាសហព័ន្ធសហគមន៍នេសាទបាន ។

វិធាន និងនីតិវិធីដើម្បីបង្កើត និងគ្រប់គ្រងសហគមន៍នេសាទ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.–**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកត.០៥០៥.២៥៥ **នរោត្តម សីហមុនី**

**បានយកសេចក្តីក្រាបបង្គំទូលថ្វាយ**

**ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា**

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ ២១៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាខឺ តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/២៤១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម ឡៅ ថេន ជាទីប្រឹក្សាផ្ទាល់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

មាត្រា ២ : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣[illegible].០៥០៥.២៥៦

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥*

លេខ [illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/២៤២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/0៧04/001 ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២004 ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២004 ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម សែម សុខណ្ណដេត ជាទីប្រឹក្សាផ្ទាល់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា ២ :** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៥០៥.២៤៧

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥*

លេខ ២០... ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរដ្ឋាភិបាល

ណាឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៤៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់ឱ្យប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៥០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម សូត្រ សម្បត្តិ ជាទីប្រឹក្សារបស់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារពាណិជ្ជកម្មក្នុង និងក្រៅប្រទេស មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស ។

**មាត្រា ២ :** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល-០៥០៦.២៥៤

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៥*

លេខ: ៥៧២១ ច.ល
**ជម្រាបជូនចំពោះ**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៦ ៩ ៧ ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៨៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **ញឹម ខេមរា** ជាអគ្គលេខាធិការរង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា ២:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**
**នរោត្តម សីហមុនី**

៣រ.ល.០៥០៦.៧៦៤

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៥*

លេខ ២១៩ . ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

**សាឌី តាន់**

៦/២

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៥០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៣ រូប ដូចមានរាយនាមខាងក្រោម :

១-វរសេនីយ៍ឯក **យិន គឹមអាន** អត្តលេខ ០០៣៣៦៣
២-វរសេនីយ៍ឯក **ថោង សារ៉ាត់** អត្តលេខ ០០១១៨៧
៣-វរសេនីយ៍ឯក **ស ចាវី** អត្តលេខ ០០១៥០០

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤ស.០៥០៦.២៦៥

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៥*

លេខ: ២២១ . ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សរ៉ែ តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៥១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់បាល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៤ រូប ដូចមានរាយនាមខាងក្រោម :

១-ឧត្តមសេនីយ៍ត្រី **ហេង សារឿន** អត្តលេខ ០០០៤៧៣
២-ឧត្តមសេនីយ៍ត្រី **សុខ សុខៈ** អត្តលេខ ០០០៤៧៤
៣-ឧត្តមសេនីយ៍ត្រី **ឡឿង សារុន** អត្តលេខ ០០២៣៣២
៤-ឧត្តមសេនីយ៍ត្រី **សុខ យ៉ាន** អត្តលេខ ០០០៨៥៧

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ : ២៦២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ហត្ថលេខា : 
សុខ ឡូ ឡាន
(signature) ណាវ៉ា តាន់

៣.៤.០៥០៦.២៦៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៦៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ . ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៤/០០២ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៥
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ២.៦៤០ លានរៀល ( ពីរពាន់ប្រាំមួយរយសែសិបលាន រៀលគត់ ) ពីជំពូក ៤១ (ចំណាយមិនបានគ្រោងទុក ) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការ ជួសជុលតូច ) ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ២០០៥ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៧៣៥....អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការបង្កើតក្រុមប្រឹក្សានីតិកម្ម និងនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ចំណុះក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះចូលមកជំនួសអនុក្រឹត្យលេខ ០៨ អនក្របក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ានចំណុះក្រសួងមហាផ្ទៃ ដែលត្រូវទុកជានិរាករណ៍ ។

# ជំពូកទី ២

## ក្រុមប្រឹក្សានីតិកម្ម

**មាត្រា ២.-**

បង្កើតក្រុមប្រឹក្សានីតិកម្មរបស់ក្រសួងមហាផ្ទៃ ដើម្បីជួយរដ្ឋមន្ត្រី ឬសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងការកសាងសេចក្តីព្រាងច្បាប់ ឬអនុក្រឹត្យនានាដែលពាក់ព័ន្ធនឹងក្រសួងមហាផ្ទៃ ។

**មាត្រា ៣.-**

សមាសភាពក្រុមប្រឹក្សានីតិកម្មរបស់ក្រសួងមហាផ្ទៃ ត្រូវតែងតាំង និងផ្លាស់ប្តូរដោយអនុក្រឹត្យ តាមការស្នើរបស់រដ្ឋមន្ត្រី ឬសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយធ្វើការជ្រើសរើសក្នុងចំណោមមន្ត្រីជាន់ខ្ពស់នៃក្របខ័ណ្ឌរដ្ឋបាល និងក្របខ័ណ្ឌនគរបាលជាតិក្រសួងមហាផ្ទៃដែលធ្លាប់មានបទពិសោធន៍ខាងការកសាងច្បាប់ ឬមានកម្រិតយល់ដឹងផ្នែកច្បាប់ ។

**មាត្រា ៤.-**

ក្រុមប្រឹក្សានីតិកម្មរបស់ក្រសួងមហាផ្ទៃមានភារកិច្ច ÷

-ពិនិត្យខ្លឹមសារនៃសេចក្តីព្រាងច្បាប់ ឬអនុក្រឹត្យ និងលិខិតបទដ្ឋាននានា ដែលអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានរដ្ឋបាល ឬអង្គភាពផ្សេងៗចំណុះក្រសួងមហាផ្ទៃ បានតាក់តែងរួចហើយមុននឹងដាក់ឆ្លងមតិថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ

-សិក្សាបំពេញបន្ថែមខ្លឹមសារៈដែលនៅចន្លោះប្រហោង ឬកាត់បន្ថយខ្លឹមសារណាដែលយល់ឃើញថា មិនសមស្រប

-ស្រាវជ្រាវ និងពិនិត្យខ្លឹមសារនៃសេចក្តីព្រាងច្បាប់ ឬអនុក្រឹត្យ និងលិខិតបទដ្ឋាននានា ធ្វើយ៉ាងណាឱ្យមានលក្ខណៈស្របគ្នាជាមួយប្រព័ន្ធច្បាប់ផ្សេងៗទៀត ដែលបានដាក់ចូលជាធរមានរួចហើយ

-ចាត់ចែងរៀបចំបំពេញបែបបទ ក្នុងការបញ្ជូនសេចក្តីព្រាងច្បាប់ ឬអនុក្រឹត្យនានាទៅរាជរដ្ឋាភិបាល ក្រោយពីមានការសម្រេចពីរដ្ឋមន្ត្រី ឬសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃរួចហើយ

-សិក្សាស្រាវជ្រាវតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋាននានា តាមសំណូមពររបស់រដ្ឋមន្ត្រី ឬសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៥.-**

មន្ត្រីរាជការទាំងអស់ ទាំងក្របខ័ណ្ឌរដ្ឋបាលស៊ីវិល ទាំងក្របខ័ណ្ឌនគរបាលជាតិដែលកំពុងបម្រើការងារនៅក្នុងរចនាសម្ព័ន្ធរបស់ក្រុមអ្នកច្បាប់ ដែលត្រូវតែងតាំងដោយអំណាចនៃអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០០ ត្រូវផ្ទេរបញ្ជូនទៅ ក្នុងអង្គភាពផ្សេងៗ ចំណុះក្រសួងមហាផ្ទៃ តាមការចាំបាច់របស់ខ្លួន ។

**មាត្រា ៦.-**

ក្រុមប្រឹក្សានីតិកម្មរបស់ក្រសួងមហាផ្ទៃ មានប្រធាន ០១ រូប អនុប្រធាន ០១ រូប និងសមាជិកមួយចំនួន តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ប្រធានក្រុមប្រឹក្សានីតិកម្ម មានឋានៈស្មើអនុរដ្ឋលេខាធិការ អនុប្រធានក្រុមប្រឹក្សានីតិកម្ម មានឋានៈស្មើអគ្គនាយករងនៃអគ្គនាយកដ្ឋាន និងសមាជិកក្រុមប្រឹក្សានីតិកម្មគ្រប់រូប មានឋានៈស្មើប្រធាននាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ។

**មាត្រា ៧.-**

សមាជិកក្រុមប្រឹក្សានីតិកម្មរបស់ក្រសួងមហាផ្ទៃ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬរបស់អនុប្រធាន ពេលប្រធានអវត្តមាន និងត្រូវបំពេញការងារផ្សេងទៀត តាមការចាត់តាំងរបស់ប្រធាន។

**មាត្រា ៨.-**

ក្រុមប្រឹក្សានីតិកម្មរបស់ក្រសួងមហាផ្ទៃ មានលេខាធិការដ្ឋានមួយ សម្រាប់ចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ធ្វើកំណត់ហេតុគ្រប់ពេលប្រជុំរបស់ក្រុមប្រឹក្សានីតិកម្ម និងធ្វើកិច្ចការផ្សេងៗទៀត តាមសំណូមពររបស់ក្រុមប្រឹក្សានីតិកម្ម ។

**មាត្រា ៩.-**

លេខាធិការដ្ឋានដឹកនាំដោយប្រធាន ០១ រូប មានឋានៈស្មើប្រធាននាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ និងមានអនុប្រធាន ០១ រូបជាជំនួយ ព្រមទាំងមន្ត្រីមួយចំនួនតាមការចាំបាច់។

## ជំពូកទី៣
## នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ចំណុះក្រសួងមហាផ្ទៃ

**មាត្រា ១០.-**

បង្កើតនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ចំណុះក្រសួងមហាផ្ទៃ ដែលមានតួនាទីភារកិច្ចដូចខាងក្រោម ÷

-សហការរៀបចំការប្រជុំសិក្ខាសាលា និងពិធីផ្សេងៗជូនថ្នាក់ដឹកនាំក្រសួង

-រៀបចំបែបបទលិខិតឆ្លងដែន ទិដ្ឋាការ និងទម្រង់បែបបទជូនថ្នាក់ដឹកនាំ និងគណៈប្រតិភូ របស់ក្រសួងមហាផ្ទៃអញ្ជើញទៅបំពេញទស្សនកិច្ចនៅបរទេស

-ទំនាក់ទំនងជាមួយស្ថានទូត និងក្រសួងនានាលើកិច្ចការអន្តរជាតិ

-ចងក្រង និងធ្វើសេចក្តីព្រាងច្បាប់ ព្រមទាំងរៀបចំពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា ជាមួយក្រសួងមហាផ្ទៃ នគរបាលជាតិ នៃប្រទេសនានា លើសកលលោក និងបកប្រែលិខិតស្នាមផ្សេងៗ

-ធ្វើទំនាក់ទំនងការងារជាមួយក្រសួងមហាផ្ទៃ និងអគ្គនគរបាលជាតិ នៃប្រទេសនានាលើការងារគ្រប់គ្រងរដ្ឋបាលដែនដី និងការងារនគរបាលជាតិ

-ស្រាវជ្រាវ និងធ្វើការវិភាគ និងគ្រប់គ្រងការងារអាស៊ាន ដែលទាក់ទិនផ្ទាល់នឹងសមត្ថកិច្ច នៃក្រសួងមហាផ្ទៃ

-ធ្វើលិខិតជូនពរឱ្យថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ក្នុងឱកាសបុណ្យជាតិនិងអន្តរជាតិ

-បូកសរុបការងារ ប្រចាំអឌ្ឍមាស ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។

**មាត្រា ១១.** -

រចនាសម្ព័ន្ធរបស់នាយកដ្ឋានទំនាក់ទំនងអន្តរជាតិរួមមាន ÷

-ការិយាល័យរដ្ឋបាល និងសរុប

-ការិយាល័យអាស៊ាន

-ការិយាល័យបកប្រែ

-ការិយាល័យអន្តរជាតិ

-ការិយាល័យពិធីការ ។

ការរៀបចំតួនាទីភារកិច្ច និងការប្រព្រឹត្តទៅរបស់ការិយាល័យនីមួយៗ នៃនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១២.** -

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយ នឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៣.** -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល ÷**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-អគ្គលេខាធិការនៃរាជរដ្ឋាភិបាល

-ដូចមាត្រា១៣

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៧៥ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា ៥ នៃអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើតអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/ ១៥៨ ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០០២ ស្តីពីការបង្កើតអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រាមួយៈ** ត្រូវបានកែសម្រួលមាត្រា ៥ នៃអនុក្រឹត្យលេខ ៨៧ អនក្រ. បក ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើតអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដូចតទៅ :

**មាត្រា៥ថ្មី:** អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នេះមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម **ស៊ុំ ម៉ានិត** | ទីប្រឹក្សារាជរដ្ឋាភិបាល | | ប្រធាន |
| ២- ឯកឧត្តម **អង្គ វង្សវឌ្ឍនា** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | | អនុប្រធាន |
| ៣- ឯកឧត្តម **សុខ ចិន្តា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | សមាជិក |
| ៤- ឯកឧត្តម **សំ សុខផល** | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | | សមាជិក |
| ៥- ឯកឧត្តម **ខី តាឃី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |
| ៦- ឯកឧត្តម **ឡៀល មួន** | សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម | | សមាជិក |
| ៧- ឯកឧត្តម **ហែម ក្រាញ់តូនី** | អនុរដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី | | សមាជិក |
| ៨- ឯកឧត្តម **ម៉ៅ ថូរ៉ា** | អនុរដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្ម | | សមាជិក |
| ៩- ឯកឧត្តម **ឆាល់ ច័ន្ទតារា** | មេធាវីរាជរដ្ឋាភិបាល | | សមាជិក |
| ១០-លោក **ភើត រិទ្ធិ** | ជំនួយការស្រាវជ្រាវនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | | សមាជិក |

**មាត្រាពីរៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ប្រធានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រាពីរ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៧៧...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរផ្លូវគោក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទិ ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០០៥ ។

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ :** បង្កើតគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរផ្លូវគោក សរសេរកាត់ថា : "គ.ស.ច.គ." ។

**មាត្រា ២ :** គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរផ្លូវគោក បង្កើតឡើងក្នុងគោលបំណង ÷

-ប្រមូលកម្លាំង ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការ កិច្ចសហការ និងការសម្របសម្រួលរវាងក្រសួង និងស្ថាប័ន ដែលពាក់ព័ន្ធ សំដៅចាត់វិធានការបង្ការ ទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរ ផ្លូវគោកឱ្យដល់កម្រិតទាបបំផុត

- ការពារអាយុជីវិតប្រជាជន និងបង្ការការខូចខាតបាត់បង់ទ្រព្យសម្បត្តិឯកជន និងសាធារណៈដែលបណ្តាលមកពីគ្រោះថ្នាក់ចរាចរ និងជាហេតុធ្វើឱ្យប៉ះពាល់ ដល់សេដ្ឋកិច្ច សង្គម និងផលិតផលសរុបក្នុងស្រុក
- ធានាឱ្យបានរឹងមាំនូវសណ្តាប់ធ្នាប់ និងសុវត្ថិភាពចរាចរផ្លូវគោក ។

**មាត្រា ៣** : គណៈកម្មាធិការជាតិ មានគណៈកម្មាធិការខេត្ត ក្រុង ជាជំនួយការ ។ គណៈកម្មាធិការជាតិមានអគ្គលេខាធិការដ្ឋានមួយ និងគណៈកម្មាធិការខេត្ត ក្រុង នីមួយៗ មានលេខាធិការដ្ឋានមួយ ។

## ជំពូកទី ២

## សមាសភាព

**មាត្រា ៤** : សមាសភាព នៃគណៈកម្មាធិការជាតិមានដូចខាងក្រោម ៖

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២-រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣-រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤-អគ្គស្នងការនគរបាលជាតិ | អនុប្រធាន |
| ៥-អគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូន | សមាជិកអចិន្ត្រៃយ៍ |
| ៦-រដ្ឋលេខាធិការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧-រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៨-រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៩-រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ១០-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១១-រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១២-រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១៣-រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៤ -រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៥ -រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៦ -រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៧ -រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៨ -មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៩ -អគ្គលេខាធិការសមាគមជាតិកាកបាទក្រហមកម្ពុជា | សមាជិក |
| ២០ -អគ្គនាយក នៃអគ្គនាយកដ្ឋានសាធារណការ | សមាជិក ។ |

**មាត្រា ៥** : សមាសភាព នៃគណៈកម្មាធិការខេត្ត ក្រុង មានដូចខាងក្រោម ÷

| | |
|---|---|
| ១-អភិបាលខេត្ត ក្រុង | ប្រធាន |
| ២-ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង | អនុប្រធាន |
| ៣-ស្នងការនគរបាលខេត្ត ក្រុង | អនុប្រធាន |
| ៤-អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង | សមាជិកអចិន្ត្រៃយ៍ |
| ៥-មេបញ្ជាការកងរាជអាវុធហត្ថខេត្ត ក្រុង | សមាជិក |
| ៦-ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្រុង | សមាជិក |
| ៧-ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង | សមាជិក |
| ៨-ប្រធានមន្ទីរបរិស្ថាន ខេត្ត ក្រុង | សមាជិក |
| ៩-ប្រធានមន្ទីរព័ត៌មាន ខេត្ត ក្រុង | សមាជិក |
| ១០-ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្ត ក្រុង | សមាជិក |
| ១១-ប្រធានមន្ទីរទេសចរណ៍ ខេត្ត ក្រុង | សមាជិក |
| ១២-ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្ត ក្រុង | សមាជិក |
| ១៣-ប្រធានសាខាកាកបាទក្រហមខេត្ត ក្រុង | សមាជិក ។ |

**មាត្រា ៦** : គណៈកម្មាធិការខេត្ត ក្រុង នីមួយៗ ត្រូវបង្កើតក្រុមការងារសុវត្ថិភាពចរាចរផ្លូវគោក នៅតាមស្រុក ខណ្ឌ ឃុំ សង្កាត់ ជាជំនួយការ ដើម្បីងាយស្រួលក្នុងការប្រមូលរបាយការណ៍ និងការងារផ្តល់ព័ត៌មាន ផ្សព្វផ្សាយពីថ្នាក់ជាតិ ទៅមូលដ្ឋាន និងពីមូលដ្ឋានទៅថ្នាក់ជាតិ ។

**មាត្រា ៧** : សមាសភាព នៃអគ្គលេខាធិការដ្ឋានរបស់ គ.ស.ច.គ. មានដូចខាងក្រោម ÷

| | |
|---|---|
| ១- អគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូន | ប្រធាន |
| ២- អគ្គនាយករង នៃអគ្គនាយកដ្ឋានសាធារណការ | អនុប្រធាន |
| ៣- ប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក | អនុប្រធាន |
| ៤- ប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៥- អនុប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក | សមាជិក |
| ៦- តំណាងប្រធាននាយកដ្ឋានផ្លូវថ្នល់ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៧- តំណាងប្រធាននាយកដ្ឋានផែនការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៨- តំណាងប្រធានមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេសសាធារណការ | សមាជិក ។ |

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ មានទីតាំងនៅអគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ៨ :** សមាសភាពរបស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការខេត្ត ក្រុង មានដូចខាងក្រោម ÷

| | |
|---|---|
| ១- ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង | ប្រធាន |
| ២- អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង | អនុប្រធាន |
| ៣- នាយការិយាល័យដឹកជញ្ជូន ខេត្ត ក្រុង | សមាជិក |
| ៤-មន្ត្រីជំនាញ ០៣នាក់ នៃការិយាល័យដឹកជញ្ជូន ខេត្ត ក្រុង | សមាជិក ។ |

លេខាធិការដ្ឋាន នៃគណៈកម្មាធិការខេត្ត ក្រុង មានទីតាំងនៅមន្ទីរសាធារណការ និងដឹកជញ្ជូន ។

## ជំពូកទី ៣
## ភារកិច្ច

**មាត្រា ៩ :** គ.ស.ច.គ.មានភារកិច្ច ÷

ក- កសាងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ សកម្មភាព គ្រប់គ្រងសន្តិសុខ សុវត្ថិភាពចរាចរផ្លូវគោក ដាក់ជូនរាជរដ្ឋាភិបាល ពិនិត្យសម្រេច ។

ខ- ដាក់ឱ្យអនុវត្តផែនការសកម្មភាពសុវត្ថិភាពចរាចរផ្លូវគោក រួមទាំងផ្លាកសញ្ញាផ្សេងៗ ។

គ- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តផែនការសកម្មភាព សុវត្ថិភាពចរាចរផ្លូវគោក ។

ឃ-ណែនាំអំពីនីតិវិធីសម្រាប់ការចាត់តាំង អនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រសកម្មភាពសុវត្ថិភាពចរាចរផ្លូវគោក ។

ង- ធ្វើសហប្រតិបត្តិការ និងកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល ដើម្បីការអនុវត្តផែនការសកម្មភាព សុវត្ថិភាពចរាចរ ឱ្យមានប្រសិទ្ធភាព។

ច- ស្វែងរកជំនួយពីបរទេស ក្រុមហ៊ុនឯកជន ឬអង្គការផ្សេងៗ។

**មាត្រា ១០ :** គណៈកម្មាធិការខេត្ត ក្រុង មានភារកិច្ច ÷

ក- អនុវត្តផែនការយុទ្ធសាស្ត្រ និងបទដ្ឋាននានា ដែលដាក់ចេញដោយគណៈកម្មាធិការជាតិ ។

ខ- លើកគម្រោងចំណាយផ្សេងៗ ប្រចាំឆ្នាំពាក់ព័ន្ធទៅនឹងវិធានការ សម្រាប់កាត់បន្ថយគ្រោះថ្នាក់ចរាចរ ។

គ- បំពេញភារកិច្ចដទៃទៀត ដែលគណៈកម្មាធិការជាតិប្រគល់អោយ ។

**មាត្រា ១១ :** អគ្គលេខាធិការដ្ឋានរបស់ គ.ស.ច.គ. មានភារកិច្ច ÷

ក- ជាសេនាធិការ និងជាជំនួយការ របស់គណៈកម្មាធិការជាតិ ។

ខ- អនុវត្តនូវរាល់សេចក្តីសម្រេច របស់គណៈកម្មាធិការជាតិ ។

គ- ចាត់ចែងផ្សព្វផ្សាយ អប់រំពន្យល់ណែនាំជាសាធារណៈ តាមគ្រប់រូបភាព និងគ្រប់មធ្យោបាយដល់អ្នកប្រើប្រាស់ផ្លូវ និងប្រជាពលរដ្ឋ ឱ្យស្គាល់ និងយល់ច្បាស់អំពីច្បាប់ និងបទប្បញ្ញត្តិចរាចរ ។

ឃ-ប្រមូលផ្តុំ និងរៀបចំគម្រោងថវិកាប្រចាំឆ្នាំ របស់គណៈកម្មាធិការជាតិ ។

ង-ប្រមូលស្ថិតិយានយន្ត គ្រោះថ្នាក់ចរាចរទូទាំងប្រទេសដើម្បីធ្វើការបូកសរុប និងវិភាគរកមូលហេតុ ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ចរាចរ រួចលើកសំណូមពរជូនរាជរដ្ឋាភិបាល ក្នុងករណីចាំបាច់ ។

ច- បណ្តុះបណ្តាលគ្រូបង្រៀន នៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈ ឯកជន និងអាជ្ញាធរមូលដ្ឋាន ដើម្បីជួយផ្សព្វផ្សាយ អប់រំ អំពីច្បាប់ចរាចរ ។

ឆ-បណ្តុះបណ្តាលធនធានមនុស្ស លើវិស័យសុវត្ថិភាពចរាចរ ដើម្បីបម្រើសេចក្តីត្រូវការក្នុងគណៈកម្មាធិការជាតិ ។

**មាត្រា ១២** : លេខាធិការដ្ឋានរបស់គណៈកម្មាធិការខេត្ត ក្រុង មានភារកិច្ច ៖

ក- ជាសេនាធិការ និងជាជំនួយការ របស់គណៈកម្មាធិការខេត្ត ក្រុង ។

ខ- អនុវត្តនូវរាល់សេចក្តីសម្រេច របស់គណៈកម្មាធិការខេត្ត ក្រុង ។

គ- រៀបចំគម្រោងចំណាយសម្រាប់សុវត្ថិភាពចរាចរផ្លូវគោកប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ ដើម្បីផ្ញើជូនគណៈកម្មាធិការខេត្ត ក្រុង ។

ឃ- ផ្សព្វផ្សាយ អប់រំ ជាសាធារណៈ ដល់អ្នកប្រើប្រាស់ផ្លូវ និងប្រជាពលរដ្ឋឱ្យស្គាល់ និងយល់ច្បាស់ពីច្បាប់ និងបទប្បញ្ញត្តិចរាចរ ។

ង- ស្រង់ស្ថិតិអំពីគ្រោះថ្នាក់ចរាចរ ដែលកើតមាននៅក្នុងខេត្ត ក្រុង និងបញ្ជូនមកអគ្គលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិ ។

ច- តាមដានសភាពការណ៍ចរាចរ និងកត់ត្រាទុកកន្លែងណា ដែលមានគ្រោះថ្នាក់ចរាចរ ញឹកញាប់ ។

## ជំពូកទី ៤
## ថវិការបស់គណៈកម្មាធិការជាតិ

**មាត្រា ១៣** : គណៈកម្មាធិការជាតិ ត្រូវមានថវិកាដោយឡែក ដែលជាឧបសម្ព័ន្ធរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ១៤** : ប្រភពថវិការបស់គណៈកម្មាធិការជាតិ រួមមាន ៖

- ថវិកាទូទៅរបស់រដ្ឋ នៃក្រសួងសាធារណការ និងដឹកជញ្ជូន
- ចំណូលបានពីការផាកពិន័យបទល្មើសចរាចរ
- ជំនួយបរទេស
- អំណោយរបស់សប្បុរសជន ក្រុមហ៊ុនឯកជន ឬអង្គការផ្សេង ៗ
- ប្រភពចំណូលផ្សេងៗទៀត ។

**មាត្រា ១៥** :- គណៈកម្មាធិការជាតិ និងគណៈកម្មាធិការខេត្ត ក្រុង ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុង ដើម្បីឱ្យដំណើរប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិ និងគណៈកម្មាធិការខេត្ត ក្រុង មានប្រសិទ្ធភាព ។

- គណៈកម្មាធិការជាតិ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។
- គណៈកម្មាធិការខេត្ត ក្រុង មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត ក្រុង ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៦ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្ត ក្រុង និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ១៨ :** អនុក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា១៧
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧៥៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស រកម ១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម ១២០៤/០០២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥
- បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីអំពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៥
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា.១.** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៣.៣០០.០០០រៀល (បីលានបីរយពាន់រៀលគត់) ពីជំពូក ១១ (ចំណាយដំណើរការរដ្ឋបាលសំភារៈ និង ការជួសជុលតូច ) មកជំពូក ៣១ ( អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ ) សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ឧបត្ថម្ភនិវត្តជន ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៣៥៩...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់
- ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧, ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤, ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣, ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥, ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែ ដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០, ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១២០៤/ ០០២, ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**សំរេច**

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៤០១ ២៦០ ០០០ រៀល( បួនរយមួយលានពីររយហុកសិបពាន់រៀលគត់ ) ពីជំពូក ៤១ ( ចំណាយមិនបានគ្រោងទុក ) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះទៅ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ការចំណាយរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃគណៈកម្មការដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម គ្រប់មុខសញ្ញា សំរាប់ឆ្នាំ ២០០៥ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនិតិសម្បទា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:......៤៧៧......អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលរាជធានីភ្នំពេញ

**សម្រេច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ចំនួន ០៣ រូប ដែលបានបរិច្ចាគ ធនធានផ្ទាល់ខ្លួន ជួយកសាងអគារសិក្សា ចំនួន ០១ ខ្នង មាន ០៣ បន្ទប់ និង ជួសជុលអគារចាស់ ចំនួន ០១ ខ្នង ទៀត នៅក្នុងសាលាបឋមសិក្សាវត្តបុទុមវត្តី រាជធានីភ្នំពេញ ដូចមានរាយព្រះនាម និង នាមខាងក្រោម ៖

១-លោកមហាព្រឹទ្ធាចារ្យ **ហ៊ុន នាង**

២-សម្តេចព្រះពោធិវង្ស **នន្ទ ង៉ែត**

៣-លោកស្រី **ស៊ុយ សុផាន**

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ០៦ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៦៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន២១គ្រឿង ប្រគេន និង ជូនសប្បុរសជន ចំនួន២១រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមជួយកសាង សាលារៀន ឧបដ្ឋានសាលា ជួសជុលព្រះវិហារ និង កសាងសមិទ្ធផលជាច្រើនទៀត នៅក្នុងពុទ្ធសីមា វត្តបាក់ខែង សង្កាត់ព្រែកលាប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដូចមានរាយព្រះនាមនិងនាម ខាងក្រោមនេះ :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-ព្រះមហាសុមេធាធិបតី **នន្ទ ងឿន** | សម្តេចព្រះសង្ឃរាជគណៈមហានិកាយ | បច្ច័យចំនួន ២៥.៤៨០ ដុល្លារ |
| ២-ព្រះវិន័យមង្គល **កែវ សម្បត្តិ** | រាជាគណៈ ថ្នាក់កិត្តិយស ទីប្រឹក្សាផ្ទាល់ សម្តេចព្រះសង្ឃរាជគណៈមហានិកាយ ព្រះវិន័យធរ ខណ្ឌដង្កោ និងជាចៅអធិការវត្តទួលអង្គក្រពើ | បច្ច័យចំនួន ១៧.៥០០ ដុល្លារ |
| ៣-ភិក្ខុ **មិន មុនខេម** | ចៅអធិការ វត្តបាក់ខែង | បច្ច័យចំនួន ១០២.៤៣១ ដុល្លារ |
| ៤-ភិក្ខុ **ឆន់ ទិមាន** | គ្រូសូត្រស្តាំ វត្តបាក់ខែង | បច្ច័យចំនួន ១៧.៤៤០ ដុល្លារ |
| ៥-ភិក្ខុ **សំ សុវណ្ណ** | គ្រូសូត្រឆ្វេង វត្តបាក់ខែង | បច្ច័យចំនួន ១៥.៦៧០ ដុល្លារ |
| ៦-ឧបាសិកា **កែវ ខាន់** | សប្បុរសជន | ថវិកាចំនួន ១៣.៤៥០ ដុល្លារ |
| ៧-លោក **រិ ស្មើ** | សប្បុរសជន | ថវិកាចំនួន ១២.០៧៧ ដុល្លារ |

៨-លោក អៀង សុផល សប្បុរសជន ថវិកាចំនួន ១២.១១៣ ដុល្លារ
៩-ឧបាសិកា ខួន ហុងសិត សប្បុរសជន ថវិកាចំនួន ១២.២១៤ ដុល្លារ
១០-លោក ម៉ា កន្ទួល សប្បុរសជន ថវិកាចំនួន ១៦.១២៥ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-ឧបាសក ក្រោន មូល សប្បុរសជន ថវិកាចំនួន ៨.៣៨៤ ដុល្លារ
២-ឧបាសក សោម មិន សប្បុរសជន ថវិកាចំនួន ៨.២៥០ ដុល្លារ
៣-អ្នកស្រី គីម លីន សប្បុរសជន ថវិកាចំនួន ៧.១៧៦ ដុល្លារ
៤-ឧបាសិកា សៀក លឹម សប្បុរសជន ថវិកាចំនួន ៧.១៥៤ ដុល្លារ
៥-ឧបាសក ញៀម ជួន សប្បុរសជន ថវិកាចំនួន ៦.១៣៧ ដុល្លារ
៦-ឧបាសក សេន មាន សប្បុរសជន ថវិកាចំនួន ៧.១៧៧ ដុល្លារ
៧-ឧបាសក ម៉ី ស្រេង សប្បុរសជន ថវិកាចំនួន ៧.២១៥ ដុល្លារ
៨-ឧបាសក សេង លាងហុក សប្បុរសជន ថវិកាចំនួន ៦.១៣៤ ដុល្លារ
៩-ឧបាសក ទិម អ៊ើន សប្បុរសជន ថវិកាចំនួន ៦.១៤០ ដុល្លារ
១០-អ្នកស្រី សោម ចំរើន សប្បុរសជន ថវិកាចំនួន ៧.២៧៥ ដុល្លារ
១១-អ្នកស្រី សេង សាម៉ុន សប្បុរសជន ថវិកាចំនួន ៧.១៨៩ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤៧៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ចំនួន១៦រូប ដែលបានបរិច្ចាគ បច្ច័យ និង ថវិកា ចូលរួមជួយកសាង អគារសិក្សា ០១ខ្នង មាន០៦បន្ទប់ និង សាលប្រជុំ ០១បន្ទប់ នៅពុទ្ធិកវិទ្យាល័យ ព្រះមេគណសាសានជាឆោម ឃុំក្រចេះ ស្រុកក្រចេះ ខេត្តក្រចេះ ដូចមានរាយព្រះនាម និង នាមខាងក្រោមនេះ :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-ព្រះគ្រូ **ជា ឆោម** | គង់នៅសហរដ្ឋអាមេរិក | បច្ច័យ ចំនួន ១៣.៥៣៩ ដុល្លារ |
| ២-លោក **ឈឹន ចាន់ថន** | នៅកាណាដា | ថវិកា ចំនួន ១០.០០០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | |
|---|---|---|
| -ព្រះគ្រូ **ឃី សុជាតិន្ទ** | គង់នៅខេត្តកំពង់ចាម | បច្ច័យ ចំនួន ៧.០០០ ដុល្លារ |

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-ឧបាសិកា **អៀប សារួប** | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១.៥០០ ដុល្លារ |
| ២-ឧបាសិកា **ហោង ឌួច** | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១.២៣០ ដុល្លារ |
| ៣-ឧបាសិកា **ហា វ៉ាន់** | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១.២០០ ដុល្លារ |
| ៤-លោក **ម៉ុន វៀនអួត** | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១.១០០ ដុល្លារ |
| ៥-ឧបាសិកា **ខៀវ ឈុំ** | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១.០០០ ដុល្លារ |

| | | | |
|---|---|---|---|
| ៦-លោក | ឈំគួ គង់ | នៅកាណាដា | ថវិកាចំនួន ១.០០០ ដុល្លារ |
| ៧-លោក | ចាប ឆន | នៅកាណាដា | ថវិកាចំនួន ១.០០០ ដុល្លារ |
| ៨-លោកស្រី | ឈើន ចំនួសិរី | នៅកាណាដា | ថវិកាចំនួន ១.០០០ ដុល្លារ |
| ៩-លោក | នៅ ទ៊ាន | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១.០០០ ដុល្លារ |
| ១០-លោក | ខេង ខុន | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១.០០០ ដុល្លារ |
| ១១-ឧបាសិកា | ឡុច ទៀត | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១.០០០ ដុល្លារ |
| ១២-ឧបាសិកា | សេង ចន្ថា | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១.០០០ ដុល្លារ |
| ១៣-លោក | ព្រំ ទ្រី | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១.៤៣០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយ ទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Sb.174

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន០៥គ្រឿង ជូន សប្បុរសជន ចំនួន០៥រូប ដែលបានបរិច្ចាគទឹកប្រាក់ផ្ទាល់ខ្លួន ចូលរួមជួយកសាង ឧបដ្ឋានសាលា និង កុដិ នៅក្នុងពុទ្ធសីមា វត្តភ្នំបាត ឃុំជើងរាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ដូចមានរាយនាមខាងក្រោមនេះ :-

**ក.មេដាយមាសស្ថាបនាជាតិ :**

-លោក **ចន ខេមរា** និង អ្នកស្រី **ចាន់ ឌន** នៅសហរដ្ឋអាមេរិក ថវិកា ១៥.០០០ ដុល្លារ

**ខ.មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-លោក **ឌុយ ស្រូ** និងអ្នកស្រី **ឡុង សៀវហេង** នៅសហរដ្ឋអាមេរិក ថវិកា ៣.៦០០ ដុល្លារ

២-ឧបាសិកា **អ៊ុច ឈុំ** នៅសហរដ្ឋអាមេរិក ថវិកា ២.៨០០ ដុល្លារ

៣-ឧបាសិកា **អោម ឌុល** នៅសហរដ្ឋអាមេរិក ថវិកា ១.៧០០ ដុល្លារ

៤-ឧបាសិកា **ខ៊ែត ស៊ុម** នៅសហរដ្ឋអាមេរិក ថវិកា ១.៧០០ ដុល្លារ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ,ថ្ងៃទី ខែ មិថុនា ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

Sb.149

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧៦ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ចំនួន០៩រូប ដែលបានបរិច្ចាគបច្ច័យ និងថវិកា ចូលរួមជួយកសាង សាលាឆាន់ និង ចេតិយ នៅក្នុងពុទ្ធសីមា វត្តអង្គជុំ ឃុំរកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដូចមានរាយព្រះនាមនិងនាមខាងក្រោមនេះ :-

**ក-មេដាយមាសស្ថាបនាជាតិ :**

១-ព្រះតេជគុណ **ចែ យឿន** ចៅអធិការនិងពុទ្ធបរិស័ទ វត្តអង្គជុំ បច្ច័យ ១០.០២៥ ដុល្លារ

២-លោក **យូ ខ៊ែត** នៅប្រទេសបារាំង ថវិកា ៤៣.១០០ ដុល្លារ

**ខ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-លោក **ឃុត ខុន** និងលោកស្រី **ឃុត សារីម** នៅសហរដ្ឋអាមេរិក ថវិកា ៤.៨៦០ ដុល្លារ

២-លោក **ចៅ ឆាងហាង** និងអ្នកស្រី **លី ស៊ុយ** នៅប្រទេសបារាំង ថវិកា ៣.៩០០ ដុល្លារ

៣-លោក **រស់ អៀត** សប្បុរសជននៅភ្នំពេញ ថវិកា ២.៥០០ ដុល្លារ

៤-លោក **តាំង ឃុយស្រេង** និងអ្នកស្រី **តាំង សៀមគាង** នៅភ្នំពេញ ថវិកា ២.៣៥០ ដុល្លារ

៥-លោក **ម៉ុង ជៀវហ៊ួ** និង **បុត្រ** នៅសហរដ្ឋអាមេរិក ថវិកា ២.១៥០ ដុល្លារ

៦-លោកស្រី **គីម ឡេង** និង **បុត្រ** នៅសហរដ្ឋអាមេរិក ថវិកា ១.៦០០ ដុល្លារ

៧-លោក **ប៊ុង គីមសែត** និងអ្នកស្រី **យូ យ៉ុម** នៅស្វាយរលំ ថវិកា ១.៩០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

S.144-145

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៧៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ៤០គ្រឿង ប្រគេន និង ជូនសប្បុរសជន ដែលបានបរិច្ចាគថវិកា ជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងវិស័យព្រះពុទ្ធសាសនា អប់រំ គមនាគមន៍ និង សង្គមកិច្ច នៅក្នុងមូលដ្ឋាន ឃុំកំពែង ស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

១-ព្រះតេជគុណ **ឃុត ឆែល** ចៅអធិការវត្តកំពែង បច្ច័យ ចំនួន ១៨.១៦២ ដុល្លារ

២-ឯកឧត្តម **កែប ជុតិមា** និងលោកជំទាវ សប្បុរសជននៅក្រុងភ្នំពេញ ថវិកា ចំនួន ១០.១១០ ដុល្លារ

៣-ឯកឧត្តម **តុប សំ** និងលោកជំទាវ **ចុល្លណារិន** សប្បុរសជននៅក្រុងភ្នំពេញ ថវិកា ចំនួន ២៥.៦៥០ ដុល្លារ

៤-ឧកញ៉ា **សុខ គង់** និងលោកជំទាវ សប្បុរសជននៅក្រុងភ្នំពេញ ថវិកា ចំនួន ១៤.០០០ ដុល្លារ

៥-ឧកញ៉ា **សុខ ហុង** និងលោកជំទាវ សប្បុរសជននៅក្រុងភ្នំពេញ ថវិកា ចំនួន ១៨.៧៦៣ ដុល្លារ

៦-លោក **ហ៊ាង ទ៉ាន់ហាន** សប្បុរសជននៅក្រុងភ្នំពេញ ថវិកា ចំនួន ១១.០៩៩ ដុល្លារ

៧-លោក **ហៀប មេ** និងលោកស្រី សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១០.៩៧០ ដុល្លារ

៨-លោក **ជា សាគន** និងលោកស្រី សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១១.២០០ ដុល្លារ
៩-លោកគ្រូ **គីម អេង** និងលោកស្រី សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៣៥.៤៣៦ ដុល្លារ
១០-អង្គការ **សុកាឃ្លាកកៃ** សប្បុរសជននៅប្រទេសជប៉ុន ថវិកា ចំនួន ២៤.០០០ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោកជំទាវ **ម៉ែន សំអន** សប្បុរសជននៅក្រុងភ្នំពេញ ថវិកា ចំនួន ៥.៥១៤ ដុល្លារ
២-លោក **តេង ថៃ** និងលោកស្រី សប្បុរសជននៅខេត្តតាកែវ ថវិកា ចំនួន ៥.៣០០ ដុល្លារ
៣-លោក **ចែត បុត្រ** សប្បុរសជននៅក្រុងភ្នំពេញ ថវិកា ចំនួន ៥.២៥០ ដុល្លារ
៤-លោក **សោម ខន** និងលោកស្រី សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៥.៩៦០ ដុល្លារ
៥-លោក **អ៊ុយ នេង** និងលោកស្រី សប្បុរសជននៅក្រុងភ្នំពេញ ថវិកា ចំនួន ៥.៤៥២ ដុល្លារ
៦-លោក **ថន សុខា** និងលោកស្រី សប្បុរសជននៅក្រុងភ្នំពេញ ថវិកា ចំនួន ៥.១៤៣ ដុល្លារ
៧-លោក **ជ ឡេង** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៥.១២៣ ដុល្លារ
៨-លោកយាយ **គីម លាង** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៥.២៣៥ ដុល្លារ

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-ឯកឧត្តមពេជ **ហាន** និងលោកជំទាវ សប្បុរសជននៅក្រុងភ្នំពេញ ថវិកា ចំនួន ១.៣០០ ដុល្លារ
២-ឧត្តមសេនីយ៍ត្រី **ឃុត ឆេ** និងលោកជំទាវ សប្បុរសជននៅក្រុងភ្នំពេញ ថវិកា ចំនួន ១.៥០០ ដុល្លារ
៣-លោក **មាស ថេង** និងលោកស្រី សប្បុរសជននៅក្រុងភ្នំពេញ ថវិកា ចំនួន ៣.៥០០ ដុល្លារ
៤-លោក **សឹង សារ៉េត** និងលោកស្រី សប្បុរសជនខ្មែររស់នៅប្រទេសកាណាដា ថវិកា ចំនួន ២.៧០០ ដុល្លារ
៥-លោក **ជា ធីឡាយ** និងលោកស្រី សប្បុរសជននៅក្រុងភ្នំពេញ ថវិកា ចំនួន ២.៣០០ ដុល្លារ
៦-លោកគ្រូ **ឡៀង គួង** និងលោកស្រី សប្បុរសជននៅខេត្តតាកែវ ថវិកា ចំនួន ១.២០០ ដុល្លារ
៧-លោក **ឈឹម សាមុត** និងលោកស្រី សប្បុរសជននៅក្រុងភ្នំពេញ ថវិកា ចំនួន ១.២០០ ដុល្លារ
៨-លោក **ខួន សារិន** និងលោកស្រី សប្បុរសជននៅខេត្តតាកែវ ថវិកា ចំនួន ១.០០០ ដុល្លារ
៩-លោក **អ៊ុយ សារិន** និងលោកស្រី សប្បុរសជននៅក្រុងភ្នំពេញ ថវិកា ចំនួន ១.២៤៤ ដុល្លារ
១០-លោកយាយ **នុយ អេង**ព្រមទាំងបុត្រ សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ២.៥០០ ដុល្លារ
១១-លោកតា **ឈាន ហាក់** និងលោកយាយ សប្បុរសជនខ្មែរនៅក្រុងភ្នំពេញ ថវិកា ចំនួន ១.៧០០ ដុល្លារ
១២-លោកយាយ **ចេង លឹម**ព្រមទាំងបុត្រ សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៣.២០០ ដុល្លារ
១៣-លោកតា **ឈាង ហេង** សប្បុរសជននៅខេត្តតាកែវ ថវិកា ចំនួន ១.០០០ ដុល្លារ
១៤-លោក **គ្រួច ចូ** និងលោកស្រី សប្បុរសជននៅខេត្តតាកែវ ថវិកា ចំនួន ១.០០០ ដុល្លារ
១៥-លោក **ចេច ឃីម** និងលោកស្រី សប្បុរសជននៅខេត្តកោះកុង ថវិកា ចំនួន ១.១០០ ដុល្លារ
១៦-អ្នកស្រី **ស្រ៊ុន សុធា** និងបុត្រ សប្បុរសជននៅក្រុងភ្នំពេញ ថវិកា ចំនួន ១.០៥០ ដុល្លារ
១៧-លោក **ខួន សន** និងលោកស្រី សប្បុរសជននៅក្រុងភ្នំពេញ ថវិកា ចំនួន ១.១០០ ដុល្លារ
១៨-លោក **តន លាងម៉េង** និងលោកស្រី សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១.០០០ ដុល្លារ

១៩-លោក **អ៊ុយ ជាំ** និងអ្នកស្រី សប្បុរសជននៅក្រុងភ្នំពេញ ថវិកា ចំនួន ១.០០០ ដុល្លារ
២០-លោកតា **ស៊ុន ស្រ៊ូ** និងលោកយាយ **ខ ស៊ីផុន** សប្បុរសជននៅខេត្តតាកែវ ថវិកា ចំនួន ១.០០០ ដុល្លារ
២១-លោក **លឹម សុគន្ធ** និងលោកស្រី សប្បុរសជននៅក្រុងភ្នំពេញ ថវិកា ចំនួន ១.៣៥០ ដុល្លារ
២២-លោក **សំ ហៀង** និងលោកស្រី សប្បុរសជននៅក្រុងភ្នំពេញ ថវិកា ចំនួន ១.២៥០ ដុល្លារ

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៤៧៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន០៩គ្រឿង ប្រគេន និង ជូនសប្បុរសជន ដែលបានបរិច្ចាគធនធាន ជួយកសាងសមិទ្ធផលផ្សេងៗ នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដូចមានរាយព្រះនាម និង នាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **ផាន់ ចាន់** | ព្រះចៅអធិការវត្តអង្គសេរី | បច្ច័យចំនួន ១០.២០០ ដុល្លារ |
| ២-ព្រះតេជគុណ | **ម៉ែន សាមឿន** | ព្រះចៅអធិការវត្តព្រះធាតុ | បច្ច័យចំនួន ១០.០៥០ ដុល្លារ |
| ៣-ព្រះភិក្ខុ | **គា សាវ៉ែត** | គង់នៅវត្តព្រះធាតុ | បច្ច័យចំនួន ១១.២០០ ដុល្លារ |
| ៤-លោក | **លី គង់អ៊ីម** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ១១.៦០០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **នឿន កុសល** | គ្រូសូត្រស្តាំវត្តអង្គសេរី | បច្ច័យចំនួន ៥.០៥០ ដុល្លារ |
| ២-លោកស្រី | **ឯម សាលី** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ៥.១០០ ដុល្លារ |

//

**គ-មេដាយសេរីវឌ្ឍស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ឧបាសិកា | **ចាន់ ណន** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ២.០០០ ដុល្លារ |
| ២-ឧបាសិកា | **ម៉េង សឿង** | សប្បុរសជននៅខេត្តតាកែវ | ថវិកាចំនួន ១.២៥០ ដុល្លារ |
| ៣-ឧបាសក | **សៅ សំនៀង** | សប្បុរសជននៅខេត្តកណ្ដាល | ថវិកាចំនួន ១.០៥០ ដុល្លារ |

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្ដាល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ៦ ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៤៧៩...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០២រូប ដែលបានឧបត្ថម្ភថវិកា ជួយកសាងអគារសិក្សា នៅសាលាបឋមសិក្សា ឈើទាលជ្រុំ ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ ដូចមានខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

- ឯកឧត្តម **ហ្វូមីអាគី តាកាហាស៊ី** ឯកអគ្គរាជទូតជប៉ុន បានឧបត្ថម្ភថវិកា ចំនួន ៤៨.៤៧៧ ដុល្លារ

**ខ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

- លោក **គេលម៉េដ្ស ម៉ែន** នាយកអង្គការទស្សនពិភពលោកកម្ពុជា ឧបត្ថម្ភថវិកា ចំនួន ២.២០០ ដុល្លារ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

.183

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤២០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ឆាំង សាយហ៊ួ** សប្បុរសជនខ្មែរ រស់នៅប្រទេសបារាំង ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន អស់ចំនួន ១២.៥២០ ដុល្លារ សំរាប់ជួយសាងសង់ កុដិ ០១ខ្នង នៅវត្តអង្គរុន ក្នុងឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

3.195

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ....៤៨២ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៣៧៩

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន១៣គ្រឿង ប្រគេន និង ជូនសប្បុរសជន ដែលបានបរិច្ចាគធនធាន ជួយកសាង សមិទ្ធផលផ្សេងៗ ក្នុងវិស័យអប់រំ និង ព្រះពុទ្ធសាសនា នៅឃុំផ្ទះកណ្តាល ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដូចមានរាយព្រះនាម និង នាមខាងក្រោម :-

**ក.មេដាយមាសស្ថាបនាជាតិ :**

១-ព្រះតេជគុណ ជួន **អៀ** ព្រះចៅអធិការវត្តផ្ទះកណ្តាល បច្ច័យចំនួន ២១.៣០០ ដុល្លារ

២-ឯកឧត្តម **ចា សុជាតិវង្ស** អភិបាលរងរាជធានីភ្នំពេញ ថវិកាចំនួន ២៥.០០០ ដុល្លារ

៣-លោក **ចេង ស្រ៊ន់** និងលោកស្រី **សេង អេងហ៊ីន** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១៦.៦៦០ ដុល្លារ

៤-ព្រះភិក្ខុ **សែម ស៊ីមាសនា** គង់នៅប្រទេសបារាំង បច្ច័យចំនួន ១១.០០០ ដុល្លារ

៥-លោក **ឈាន លីមហ៊ាង** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១៥.០០០ ដុល្លារ

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោក **ស៊ាន ហ៊ាន់ហេង** សប្បុរសជនទៅភូមិឫស្សីស្រុក ខេត្តកំពង់ចាម ថវិកាចំនួន ៩.៣០០ដុល្លារ

២-លោក **លីម ទ្រី** សប្បុរសជននៅក្រុងភ្នំពេញ ថវិកាចំនួន ៥.៦០០ ដុល្លារ

**គ-មេដាយសេរីវឌ្ឍនជាតិ :**

| | | | |
|---|---|---|---|
| ១-ព្រះភិក្ខុ | **ជា ចឺត** | គង់នៅវត្តផ្ទះកណ្តាល | បច្ច័យចំនួន ១.២៥០ ដុល្លារ |
| ២-លោក | **ម៉ៅ អោភ** | សប្បុរសជននៅភូមិឫស្សីស្រុក ខេត្តកំពង់ចាម | ថវិកាចំនួន ១.៦០០ដុល្លារ |
| ៣-លោក | **ឈុច វណ្ណា** | នាយកសាលាផ្ទះកណ្តាល | ថវិកាចំនួន ១.៣៤០ ដុល្លារ |
| ៤-លោកអាចារ្យ | **អ៊ុច ចំរុយ** | គណៈកម្មការវត្តផ្ទះកណ្តាល | ថវិកាចំនួន ១.២៨០ ដុល្លារ |
| ៥-លោកអាចារ្យ | **នូ សុត** | គណៈកម្មការវត្តផ្ទះកណ្តាល | ថវិកាចំនួន ១.៤៥០ ដុល្លារ |
| ៦-លោក | **វស់ អ៊ឹម** | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១.២០០ ដុល្លារ |

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៣ ខែ ៦ ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤៥៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

ពាក្យ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០២រូប ដែលបានបរិច្ចាគថវិកា ជួយកសាងសំណង់ផ្សេងៗ ក្នុងយោធភូមិភាគទី២ ដូចមានរាយនាមខាងក្រោម :-

១-លោកវរសេនីយ៍ទោ **ឈឹម លីន** សប្បុរសជន នៅក្រុងភ្នំពេញ ឧបត្ថម្ភថវិកាចំនួន ១២.២០០ ដុល្លារ

២-លោកវរសេនីយ៍ឯក **ចាន់ឡ បូណា** សប្បុរសជន នៅក្រុងភ្នំពេញ ឧបត្ថម្ភថវិកាចំនួន ១១.៧០០ ដុល្លារ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

B.185

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤៧៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០២គ្រឿង ជូនសប្បុរសជន ដែលបានឧបត្ថម្ភថវិកាជួយកសាង អគារសិក្សា នៅសាលាបឋមសិក្សា ទួលពុទ្រា និង អនុវិទ្យាល័យជំណាក់ត្រាច ក្នុងស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ចំណាយអស់ទឹកប្រាក់សរុប ចំនួន ៥២.២៨១ ដុល្លារ ដូចមានខាងក្រោម :-

១-ឯកឧត្តម **TAKAHASHI FUMIAKI** ឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា

២-លោក **TAL MAGEPAYNE** ប្រធានអង្គការទស្សនពិភពលោកប្រចាំព្រះរាជាណាចក្រកម្ពុជា

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្ត អនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ [illegible] ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

B.187

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៩៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

* * *

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស / រកត / ០៣០០ / ១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញ ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានដាក់ឱ្យចូលនិវត្តន៍តាមមុខតំណែងលោក **ស៊ុខ** ទាវ ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នៅថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៥ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ មិថុនា ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:.....៤៧៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
ពាក្យ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការ បង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ចំនួន ០៧រូប ដែលបានបរិច្ចាគ ធនធាន និង កម្លាំងកាយចិត្ត ចូលរួមកសាងព្រះពុទ្ធសាសនា និង សង្គមជាតិ ដូចមានរាយព្រះនាម និង នាម ខាងក្រោម :-

| | | | | |
|---|---|---|---|---|
| ១-ឧបាសក | អំ | សុខ | ទឹកប្រាក់ | ៤០.៥៧០ USD |
| ២-ឧបាសិកា | ឧន់ | ជាវលី | ទឹកប្រាក់ | ៣០.៨០០ USD |
| ៣-ព្រះមង្គលមុនី | ឌេព | ផាន | បច្ច័យ | ២០.២០០ USD |
| ៤-ព្រះគ្រូបរិត្តវិទូ | នៅ | សន | ទឹកប្រាក់ | ១៥.៦០០ USD |
| ៥-ឧបាសក | ពៅ | ញឹម | ទឹកប្រាក់ | ១៤.០៥០ USD |

៦-ឧបាសក **ឈឹម សាំង** ទឹកប្រាក់ ១៣.៤០០ USD

៧-លោក **កេង ចំរើន** ទឹកប្រាក់ ១០.២៣០ USD

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៤៦ អនក្រ.បក.ថ្ង

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
៣៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះតេជគុណ **គីម សុខតាក** *(Holy Kim Sung Taik)* ដែលបានបរិច្ចាគថវិកាជាច្រើន ក្នុងការនិមន្តព្រះសង្ឃកម្ពុជា ចំនួន២០០អង្គ អោយទៅធ្វើទស្សនកិច្ចនៅសាធារណរដ្ឋកូរ៉េ ក្នុងបំណងជួយទ្រទ្រង់ និង អភិវឌ្ឍន៍វិស័យព្រះពុទ្ធសាសនា នៅកម្ពុជា ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

SK.64

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៧៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៣១

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

### សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី **ស៊ីន ជាន់យូ** (*Ms.Shin Hyun Joo*) ជាអ្នកបណ្តាក់ទុនវិនិយោគនៅកម្ពុជា ដែលបានបរិច្ចាគថវិកា ក្នុងបំណងជួយទ្រទ្រង់ និង ជំរុញការអភិវឌ្ឍន៍វិស័យកីឡាបាល់ទាត់ ក្នុងក្របខ័ណ្ឌយុវជនកម្ពុជា មានទឹកប្រាក់ ចំនួន ១០.០០០ ដុល្លារអាមេរិក ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

SK.62

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៥៨.អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦ /១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា ១ :** តែងតាំងលោក អ៊ុម សុភី ជាប្រធាននាយកដ្ឋានអាមេរិក នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៥

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ហ៊ុន សែន

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤២៣ អនក្រ.[illegible]

# អនុក្រឹត្យ
# ស្ដីពីការជូនមេដាយសហមេត្រី
៣៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនចំពោះ លោកវរសេនីយ៍ឯក *Nikólay V. NIKOLAYUK* អនុព័ន្ធយោធា សហព័ន្ធរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អក្នុងការពង្រឹង និង លើកស្ទួយទំនាក់ទំនងមិត្តភាព និង កិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរ ។

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួលៈ**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច

SR.74 - ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៩០ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកណ្តាល

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេនសម្តេចព្រះឧត្តមចរិយា **អ៊ំ លឹមហេង** ដែលមានស្នាព្រះហស្ត ព្រមទាំងព្រះគុណបំណាច់ខ្ពស់ ក្នុងការកសាង និង អភិវឌ្ឍន៍វិស័យព្រះពុទ្ធសាសនា និង សង្គមជាតិ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ចនិងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃសវនកម្ម ផ្ទៃក្នុង នៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ស ម្រេ ច

**មាត្រា១** : ត្រូវបានផ្ទេរភារកិច្ច លោក **ឌី សុភីន** ពីប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មកជាប្រធានសវនកម្មផ្ទៃក្នុង នៃទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈ**ស្មើប្រធាន-នាយកដ្ឋាន** ។

**មាត្រា២** : ត្រូវបានតែងតាំងលោក **ឡាំ ហេងហួត** ជាប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធនិងសាមីខ្លួន ដូចមាន ចែងក្នុងមាត្រា១ និងមាត្រា២ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនិងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ.

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៧២ . អនក្រ . បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យ លេខ១៣ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា ១:** ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការនៃក្រសួងធម្មការ និងសាសនា ចំនួន ០៣ រូប ដូចមានរាយនាមខាងក្រោម :

១- លោកស្រី **តែម សុធារី** ជាប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
២- លោក **ទិន សុខហាន់** ជាប្រធាននាយកដ្ឋានស្រាវជ្រាវអប់រំ និងផ្សព្វផ្សាយធម៌ទេសនា
៣- លោក **ស៊ឹម យូន** ជាប្រធាននាយកដ្ឋានធម្មការ ។

**មាត្រា ២:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី អគ្គលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៥
នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៨៣ អនក្រ-តត

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * ***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

### សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោកស្រី **យុ ស៊ីនីម** ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ [illegible] ឆ្នាំ ២០០៥*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ២
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤១៥៤ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ហាបនាជាតិ

១៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **មូន ឆាងហា** ( *Mr. Moon Chang Ha* ) ប្រធានក្រុមហ៊ុន *មូងឆាង កូអិលធីឌី* ( *Moon Chang Co.LTD* ) នៅប្រទេសកូរ៉េ ដែលបានផ្តល់ស្បែកជើងបាល់ទាត់ ចំនួនមួយកុងតឺន័រ ដល់សមាគមក្រុមបាល់ទាត់យុវជនកម្ពុជា ដែលគិតជាទឹកប្រាក់ ចំនួន ៩០.០០០ ដុល្លារអាមេរិក ដើម្បីជំរុញការអភិវឌ្ឍន៍វិស័យកីឡាបាល់ទាត់ ក្នុងក្របខ័ណ្ឌយុវជនកម្ពុជា ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

SK.76

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៦៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ចំនួន០១គ្រឿង ជូនឧកញ៉ា មហាឧបាសិកា **ញឹក ប៊ុនឆាវ** អនុប្រធានក្រុមប្រឹក្សាភិបាលសហព័ន្ធយុវជនពុទ្ធសាសនិកកម្ពុជា និង ជាប្រធានគណៈកម្មការអប់រំសីលធម៌នៃពុទ្ធិកសមាគមកម្ពុជរដ្ឋ ដែលមានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ក្នុងការអភិវឌ្ឍន៍លើវិស័យព្រះពុទ្ធសាសនា ដោយបានជួយកសាងសមិទ្ធផលជាច្រើន ពិសេសបានជួយកសាងព្រះពុទ្ធរូបអំពីមាសសុទ្ធ មានដាំត្បូងពេជ្រលំអ ចំនួន៣០គ្រាប់ និងត្បូងរតនគីរី ចំនួន២៥គ្រាប់ ទម្ងន់ ១.២ គីឡូក្រាម ទុកជាសម្បត្តិវប្បធម៌ជាតិ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងនាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

PS-100

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤១៦ អនក.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៩រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអគារសិក្សា ០១ខ្នង មាន០៣បន្ទប់ ឧបដ្ឋានសាលា សាលាបាលី កុដិ ខ្លោងទ្វារ និងសមិទ្ធផលនានាជាច្រើនទៀត នៅសាលាបឋមសិក្សាព្រះពន្លា និងនៅ វត្តរាជនីនិវេសនារាម ឃុំព្រះពន្លា ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោមនេះ :-

**ក-មេដាយមាសស្ថាបនាជាតិ :**

១-លោកស្រី **ចៅ គីមអេង** នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១៩.៤០០ ដុល្លារ

២-លោក **ជាង ឃៀង** និងលោកស្រី **ចៅ ឈីម** នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១១.៦៥០ ដុល្លារ

៣-លោក **ហេង គិមហោ** និងលោកស្រី **នុង សារុំ** នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១១.១២០ ដុល្លារ

៤-លោក **ជូ ប៊ុនហូ** នៅសហរដ្ឋអាមេរិក ថវិកាចំនួន ២២.២០០ ដុល្លារ

៥-លោកស្រី **ចុង គីមនិញ** នៅខេត្តបន្ទាយមានជ័យ ថវិកាចំនួន ១១.០០០ ដុល្លារ

៦-លោកស្រី **ចុង គីមយក់** នៅខេត្តបន្ទាយមានជ័យ ថវិកាចំនួន ១០.៥០០ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោក **អិន សាគុណ** និងលោកស្រី **ឆាន់ ផាន់ណា** នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៦.២០០ ដុល្លារ

២-លោក **ឆាន់ ទូន** និង លោកស្រី **ចៅ ឆន់** នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៥.៣៥០ ដុល្លារ

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

-លោក **ហាច ទូស៊ីច** និង លោកស្រី **ចៅ ឌូច** នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៣.៨៥០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

PS40-41

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤៩៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន២០រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងអគារសិក្សា ០១ខ្នង ព្រះវិហារ សាលាធម្មសភា សាលាឆាន់ កុដិ និង សមិទ្ធផលនានាមួយចំនួនទៀត នៅសាលាបឋមសិក្សាសៃសិន និងនៅក្នុងវត្តសមាធិផលឃុំព្រះពន្លា ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដូចមានរាយព្រះនាម និង នាមខាង ក្រោមនេះ :-

**ក-មេដាយមាសស្ថាបនាជាតិ :**

១-លោក **ឌុយ ឃួន** សប្បុរសជនខ្មែររស់នៅប្រទេសកាណាដាថវិកាចំនួន ១២.៥៣០ដុល្លារ

២-លោកស្រី **ស៊ុម សារី** សប្បុរសជនខ្មែររស់នៅប្រទេសកាណាដា ថវិកាចំនួន ១០.៥៤៨ ដុល្លារ

៣-លោក **ឃួន ម៉ៅ** សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកាចំនួន ១០.០០០ដុល្លារ

៤-លោក **ជូ ប៊ុនធា** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១០.១៨០ដុល្លារ

៥-លោកស្រី **ចៅ គីមអេង** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១០.៤៣០ដុល្លារ

៦-លោក **ឆៃ នរិន្ទ** និងលោកស្រី **អាន់ គីមណាយ** នៅខេត្តបន្ទាយមានជ័យ ថវិកាចំនួន ១០.១៥០ដុល្លារ

៧-ឯកឧត្តម **ស៊ីន្ធ គីរី** និងលោកជំទាវ អនុរដ្ឋលេខាធិការក្រសួងការពារជាតិ ថវិកា ១០.២១២ ដុល្លារ

៨-លោក **មុយ ឆួ** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១២.៦១០ដុល្លារ

៩-លោកស្រី **គោត ទៀន** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១១.២០០ដុល្លារ

១០-លោក **ទាន់ ទន្សអៀប** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១០.២៥០ដុល្លារ

១១-លោក **អ៊ិត ឈាង** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១០.១៦០ដុល្លារ

១២-លោក **ជាង យឿង** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១១.៨៧០ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-ព្រះតេជគុណ **ម៉ុក ខុន** ចៅអធិការវត្តសមាធិផល បច្ច័យចំនួន ៥.១៤០ ដុល្លារ

២-លោកស្រី **ចៅ ឈឹង** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៧.២៨០ ដុល្លារ

**គ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

១-លោក **មួង ឈិត** អាចារ្យវត្តសមាធិផល ថវិកាចំនួន ២.៤៨៥ ដុល្លារ

២-លោក **ស្រ៊ុន សុខ** គណៈកម្មការសាងសង់ ថវិកាចំនួន ២.៣៧០ដុល្លារ

៣-លោកស្រី **ផាយ សាគំ** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ២.១៧៦ ដុល្លារ

៤-លោក **មុយ ទន្តី** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៣.៦៧០ ដុល្លារ

៥-លោក **អ៊ិន សាគន** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ២.២៣០ ដុល្លារ

៦-លោកស្រី **តាន់ គាន់យ៉ា** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ២.៣៤០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

PS.37-38

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤១៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៥រូប ដែលបានបរិច្ចាគធនធាន ផ្ទាល់ខ្លួន ចូលរួមជួយកសាងអគារសិក្សា ០១ខ្នង មាន០៦បន្ទប់ ស្ពាន០១កន្លែង និងសមិទ្ធផលនានាជា ច្រើនទៀត នៅក្នុងឃុំស្រះជីក ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោមនេះ :-

| | | | |
|---|---|---|---|
| ១-លោក | **ជាង ឃៀង** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ថវិកា ១២.០០០ ដុល្លារ |
| ២-លោកស្រី | **ចៅ ឈឹម** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ថវិកា ១២.០០០ ដុល្លារ |
| ៣-លោក | **ចៅ ទ៉ា** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ថវិកា ១០.១៦៩ ដុល្លារ |
| ៤-លោកស្រី | **ស៊ុំ កូឡាប** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ថវិកា ១០.១២០ ដុល្លារ |
| ៥-លោក | **ស្រ៊ុន សុខ** | សប្បុរសជននៅខេត្តបន្ទាយមានជ័យ | ថវិកា ១០.០៦៥ ដុល្លារ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

PS46

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៦២ អនក.បក

# អនុក្រឹត្យ
## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ចំនួន ០២រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមជួយកសាង សាលាពុទ្ធិកបឋមសិក្សា សាលាធម្មសភា ជួសជុលដំបូលព្រះវិហារ និង សមិទ្ធផលមួយចំនួនទៀត នៅក្នុងពុទ្ធសីមា វត្តអង្គលំទង ឃុំស្នំក្រពើ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដូចមានរាយព្រះនាមនិងនាមខាងក្រោមនេះ :-

១-ព្រះតេជគុណ **អ៊ូត ជា** ព្រះចៅអធិការវត្ត អង្គលំទង បច្ច័យ ចំនួន ១០.៥០០ ដុល្លារ
២-អ្នកស្រី **គង ប៊ូចាន់ថន** នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៣០.៣០៥ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

S.147

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារសម្រាប់បំភ្លឺទៅនឹងមតិជំទាស់ ជាមួយនយោបាយដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា

-----------

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសភាពការណ៍ចាំបាច់

## សម្រេច

**ប្រការ១ :** ត្រូវបានបង្កើតក្រុមការងារសម្រាប់ឆ្លើយបំភ្លឺទៅនឹងមតិជំទាស់ជាមួយនយោបាយដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម :

- ឯកឧត្តម **យឹម ឆៃលី** ប្រធានក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រធាន
- ឯកឧត្តម **ព្រុំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន
- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **អ៊ុក ប្រាជ្ញា** រដ្ឋលេខាធិការក្រសួងព័ត៌មាន អនុប្រធាន
- ឯកឧត្តម **ពិត ចំណាន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិក
- ឯកឧត្តម **ចំរុង តុងអ៊ីវ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ សមាជិក
- ឯកឧត្តម **យិន គឹមស៊ាន** រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក
- ឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក
- ឯកឧត្តម **អ៊ី ធន** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក
- ឯកឧត្តម **ពេជ្រ សោភ័ណ** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

- ឯកឧត្តម **សយ ស៊ីផុន** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
- ឯកឧត្តម **នុត ណារ៉ាង** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
- ឯកឧត្តម **ស្វាយ ស៊ីថា** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- ឯកឧត្តម **សយ សុខា** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- ឯកឧត្តម **ស៊ាន វិសុទ្ធ** ប្រធានស្តីទី អង្គភាពប្រឆាំងរាល់សកម្មភាពអំពើពុករលួយ សមាជិក
- ឯកឧត្តម **តិច សំណាង** អគ្គលេខាធិការ នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំ នៃកម្ពុជា សមាជិក
- ឯកឧត្តម **កែវ វិចិត្រ** អគ្គលេខាធិការស្តីទី នៃក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ លេខាធិការ

**ប្រការ២ :** ក្រុមការងារនេះមានភារកិច្ច :

-សិក្សាស្រាវជ្រាវ ត្រៀមឯកសារពាក់ព័ន្ធ និងកសាងអត្ថបទ អំណះអំណាង ឬទឡ្ហីករណ៍នានា ដើម្បីឆ្លើយបំភ្លឺទៅនឹងមជ្ឈដ្ឋានដែលបានលើកឡើងមួយចំនួន ប្រឆាំងនឹងនយោបាយដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

-អញ្ជើញតំណាងក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធមករាយការណ៍បំភ្លឺតាមការចាំបាច់។

-ធ្វើរបាយការណ៍អំពីលទ្ធផល និងលើកវិធានការដោះស្រាយជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីចាត់ការបន្តទៀត។

**ប្រការ៣ :** សមាជិកក្រុមការងារនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ក្រុមការងារនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ. ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចប្រការ ៤
- ឯកសារ កាលប្បវត្តិ

Ans

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ៖ ៧៩០ សហវ.ប្រក.

# ប្រកាស

## ស្តីពី

## ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ ២០០៥

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ ២៤/ក្រ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ ១៩៩១ ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ១៩៩១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៤/០០២ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៥ ។

## សំរេច :

**ប្រការ១.-** ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៥ ត្រូវប្រមូលចាប់ពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៥ រហូតដល់ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៥ ។

**ប្រការ២.-** ដើម្បីបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៥ ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ត្រូវបំពេញលិខិតប្រកាសចំនួន ០២ សន្លឹក តាមគំរូឯកភាពរបស់នាយកដ្ឋានពន្ធដារ ព្រមទាំងបង្ហាញ និង ប្រគល់ជូនមន្ត្រីដែលមានសមត្ថកិច្ចនូវបង្កាន់ដៃបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៤ ដើម្បីជាភស្តុតាងបញ្ជាក់ថា មធ្យោបាយដឹកជញ្ជូន និង យានជំនិះនោះបានបង់ពន្ធសំរាប់ឆ្នាំ ២០០៤ រួចហើយ ។

**ប្រការ៣.-** ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទណាពុំមានបង្កាន់ដៃពន្ធបញ្ជាក់ថាបានបង់ពន្ធឆ្នាំ ២០០៤ ទេនោះ ត្រូវបង់ប្រាក់ពន្ធសំរាប់ឆ្នាំ ២០០៤ និង ត្រូវបង់ប្រាក់ពិន័យដែលមានចំនួនស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតឱ្យបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៥ ។

**ប្រការ៤.-** ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទណាដែលបាត់បង្កាន់ដៃបង់ពន្ធសំរាប់ឆ្នាំ ២០០៤ ម្ចាស់មធ្យោបាយ និង យានជំនិះនោះ ត្រូវមានលិខិតបញ្ជាក់ថា បានបង់ពន្ធសំរាប់ឆ្នាំ ២០០៤ ចេញដោយរដ្ឋបាលសារពើពន្ធនៃទីកន្លែងដែលបានបង់ពន្ធសំរាប់ឆ្នាំ ២០០៤ ឬត្រូវប្រកាសបង់ពន្ធនៅទីកន្លែងដែលបានបង់ពន្ធឆ្នាំ ២០០៤ ដើម្បីមានការងាយស្រួលបញ្ជាក់ផ្ទៀងផ្ទាត់ជាមួយគល់ប័ណ្ណបង្កាន់ដៃបង់ពន្ធឆ្នាំ ២០០៤ ដែលផ្នែកពន្ធរក្សាទុក ។

**ប្រការ៥.-** ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ត្រូវកំណត់លើគ្រប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដោយមិនគិតថាជារបស់រដ្ឋ ឬឯកជនឡើយទៅតាមប្រភេទនីមួយៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធ ១ និង ២ ភ្ជាប់ជាមួយនឹងប្រកាសនេះ ។

**ប្រការ៦.-** ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះនេះ ត្រូវបានលើកលែងចំពោះ :

- រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គីភ័យរបស់រដ្ឋ ។
- មធ្យោបាយដឹកជញ្ជូន និង យានជំនិះជាកម្មសិទ្ធរបស់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបំរើឱ្យការងារសំរាប់កិច្ចការពារប្រទេស សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម ។
- មធ្យោបាយដឹកជញ្ជូន និង យានជំនិះរបស់បេសកកម្មទូត ឬកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ។

**ប្រការ៧.-** ក្រោយពេលបង់ពន្ធបានត្រឹមត្រូវរួចហើយ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗ ត្រូវបានទទួលបង្កាន់ដៃបង់ពន្ធមួយសន្លឹក និង ប័ណ្ណសំគាល់មួយសន្លឹកសំរាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូន និង យានជំនិះនីមួយៗនោះ ។

បង្កាន់ដៃបង់ពន្ធនេះមានបិទត្រាជាសញ្ញាណទឹកប្រាក់ រចនាដោយអក្សរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរូបហង្សត្រួតពីលើ និង មានពន្លឺប្រាំពីរពណ៌ ដែលត្រូវថែរក្សាទុកកុំឱ្យបាត់បង់ និងត្រូវយកជាប់ជាមួយសំរាប់ទុកបង្ហាញមន្ត្រីត្រួតពិនិត្យដែលមានសមត្ថកិច្ច និង ទុកជាឯកសារសំរាប់បង់ពន្ធឆ្នាំ ២០០៦ ។

**ប្រការ៨.-** សំរាប់ឆ្នាំ ២០០៥ ប័ណ្ណសំគាល់ដែលត្រូវបិទភ្ជាប់នឹងមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទមានរូបភាព និង លក្ខណៈសំគាល់ដូចខាងក្រោម :

**១.ប័ណ្ណរាងឆកោណ :**

នៅខាងលើបំផុតនៃប័ណ្ណមានអក្សរ "ព្រះរាជាណាចក្រកម្ពុជា" ។ ខាងក្រោមបំផុតមានអក្សរ "ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ" ។ នៅកណ្តាលមានលេខ "២០០៥" សញ្ញារូបហង្ស និង មានអក្សរ "ប័ណ្ណបង់ពន្ធរថយន្ត" កាត់ពាក់កណ្តាលសញ្ញារូបហង្ស និងត្រួតលើលេខ "២០០៥" ។ ខាងក្រោម "ប័ណ្ណបង់ពន្ធរថយន្ត" មានសរសេរចំនួនប្រាក់ពន្ធ ។ ខាងក្រោមលេខកំណត់ចំនួនទឹកប្រាក់ពន្ធ មានសរសេរលេខរៀងនៃប័ណ្ណនីមួយៗ ។ នៅផ្នែកខាងមុខប័ណ្ណ មានបិទក្រដាសពណ៌ទឹកប្រាក់ រចនាដោយអក្សរក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានរូបហង្សត្រួតពីលើ និង មានពន្លឺប្រាំពីរពណ៌ ។

ប័ណ្ណរាងឆកោណនេះមាន ១២ ពណ៌គឺ :

- **ប័ណ្ណពណ៌លឿងខ្ចី ប្រើសំរាប់ :**
  + ត្រាក់ទ័រមានកម្លាំង ៣៥ សេះ
  + ត្រាក់ទ័រមានកម្លាំង ៦៥ សេះ
  + ត្រាក់ទ័រមានកម្លាំង ៨២ សេះ
- **ប័ណ្ណពណ៌បៃតង ប្រើសំរាប់ :**
  + រថយន្តទេសចរណ៍កម្លាំងដល់ ៩ សេះ គិតពីឆ្នាំផលិតលើសពី ៥ ឆ្នាំ
- **ប័ណ្ណពណ៌ផ្ទៃមេឃ ប្រើសំរាប់ :**
  + រថយន្តទេសចរណ៍កម្លាំង ៩ សេះ គិតពីឆ្នាំផលិតដល់ ៥ ឆ្នាំ
  + រថយន្តទេសចរណ៍កម្លាំងលើសពី ៩ សេះ ដល់ ១២ សេះ គិតពីឆ្នាំផលិតលើស ៥ ឆ្នាំ
- **ប័ណ្ណពណ៌ខៀវខ្ចី ប្រើសំរាប់ :**
  + រថយន្តដឹកទំនិញដល់ ៣ តោន
  + រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥ កៅអី
  + រថយន្តទេសចរណ៍កម្លាំងលើសពី ៩ សេះ ដល់ ១២ សេះ គិតពីឆ្នាំផលិតដល់ ៥ ឆ្នាំ
- **ប័ណ្ណពណ៌លឿងទុំ ប្រើសំរាប់ :**
  + រថយន្តទេសចរណ៍កម្លាំងលើសពី ១២ សេះ ដល់ ១៧ សេះ គិតពីឆ្នាំផលិតលើសពី ៥ ឆ្នាំ
- **ប័ណ្ណពណ៌ស ប្រើសំរាប់ :**
  + រថយន្តដឹកអ្នកដំណើរចុនមធ្យមមានកៅអីពី ១៦ ដល់ ២៥ កៅអី
- **ប័ណ្ណពណ៌ស្វាយ ប្រើសំរាប់ :**
  + រថយន្តដឹកទំនិញលើសពី ៣ តោន ដល់ ១០ តោន
  + រ៉ឺម៉កសណ្តោង ដល់ ១០ តោន

+ រថយន្តដឹកអ្នកដំណើរចុះធំមានកៅអីលើសពី ២៥
+ រថយន្តទេសចរណ៍កម្លាំងលើសពី ១២ សេស ដល់ ១៧សេស គិតពីឆ្នាំផលិតដល់ ៥ ឆ្នាំ

- **ប័ណ្ណពណ៌ទឹកប៊ិច ប្រើសំរាប់ :**

+ រថយន្តដឹកទំនិញលើសពី ១០ តោន ដល់ ២០ តោន
+ រ៉ឺម៉កសណ្តោងលើសពី ១០ តោន ដល់ ២០ តោន

- **ប័ណ្ណពណ៌ផ្កាឈូក ប្រើសំរាប់ :**

+ រថយន្តដឹកទំនិញលើសពី ២០ តោន
+ រ៉ឺម៉កសណ្តោងលើសពី ២០ តោន

- **ប័ណ្ណពណ៌ត្រួយចេក និង បៃតង ប្រើសំរាប់ :**

+ រថយន្តទេសចរណ៍កម្លាំងលើសពី ១៧ សេស ដល់ ២៤សេស គិតពីឆ្នាំផលិតលើសពី ៥ ឆ្នាំ

- **ប័ណ្ណពណ៌លឿងខ្ចី និង ទឹកប៊ិច ប្រើសំរាប់ :**

+ រថយន្តទេសចរណ៍កម្លាំងលើសពី ១៧ សេស ដល់ ២៤សេស គិតពីឆ្នាំផលិតដល់ ៥ ឆ្នាំ

- **ប័ណ្ណពណ៌ផ្ទៃមេឃ និង ផ្កាឈូក ប្រើសំរាប់ :**

+ រថយន្តទេសចរណ៍កម្លាំងលើសពី ២៤សេស ឡើងទៅ

**២. ប័ណ្ណរាងរង្វង់មូល :**

នៅខាងលើបំផុតមានអក្សរ "ព្រះរាជាណាចក្រកម្ពុជា" ។ ខាងក្រោមបំផុតមានអក្សរ "ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ" ។ នៅកណ្តាលប័ណ្ណមានលេខ "២០០៥" សញ្ញារូបហង្ស និង មានអក្សរ "ប័ណ្ណបង់ពន្ធទោចក្រយានយន្ត" កាត់ពាក់កណ្តាលសញ្ញារូបហង្ស និង ត្រួតលើលេខ "២០០៥" ។ ខាងក្រោម "ប័ណ្ណបង់ពន្ធទោចក្រយានយន្ត" រាងរង្វង់មូល ពណ៌លឿងទុំ និង ពណ៌ខៀវខ្ចី មានសរសេរចំនួនទឹកប្រាក់ពន្ធ ខាងក្រោមលេខកំណត់ចំនួនទឹកប្រាក់ពន្ធ មានសរសេរ លេខរៀងនៃប័ណ្ណនីមួយៗ ។ ដោយឡែកប័ណ្ណរាងរង្វង់មូលពណ៌បៃតង ពុំមានចារិកចំនួនប្រាក់ពន្ធទេ ។

ប័ណ្ណរាងរង្វង់មូលនេះមាន ៣ ពណ៌គឺ :

- **ប័ណ្ណពណ៌លឿងទុំ ប្រើសំរាប់ :**

+ ទោចក្រយានយន្តទំហំពិសស្តុងដល់ ៧០ សម៣

- **ប័ណ្ណពណ៌ខៀវខ្ចី ប្រើសំរាប់ :**

+ ទោចក្រយានយន្តមានទំហំពិសស្តុងលើសពី ៧០សម៣ ទៅ ១២៥ សម៣

- **ប័ណ្ណពណ៌បៃតង ប្រើសំរាប់ :**

+ ទោចក្រយានយន្តមានទំហំពិសស្តុងលើសពី ១២៥ សម៣ ឡើងទៅ ដែលមានទឹកប្រាក់ពន្ធចំនួន ៧,៥០០ រៀល
+ ត្រីចក្រយានយន្តដឹកទំនិញ ឬអ្នកដំណើរ ដែលមានទឹកប្រាក់ពន្ធចំនួន ១៥,០០០ រៀល

**៣. ប័ណ្ណរាងពងក្រពើ :**

នៅខាងលើបំផុតមានអក្សរ "ព្រះរាជាណាចក្រកម្ពុជា" ។ ខាងក្រោមបំផុតមានអក្សរ "ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ" ។ នៅកណ្ដាលប័ណ្ណមានអក្សរ និងលេខ "២០០៥" សញ្ញារូបហង្ស និង មានអក្សរ "ប័ណ្ណបង់ពន្ធជលយាន" កាត់ពាក់កណ្ដាលសញ្ញារូបហង្ស និង ត្រួតលើលេខ "២០០៥" ។ ខាងក្រោម "ប័ណ្ណបង់ពន្ធជលយាន" មានលេខរៀងនៃ ប័ណ្ណនីមួយៗ ។ ប័ណ្ណរាងពងក្រពើនេះ ពុំមានចារិកចំនួនប្រាក់ពន្ធទេ ។

ប័ណ្ណរាងពងក្រពើនេះមាន ៣ ពណ៌គឺ :

**- ប័ណ្ណពណ៌លឿងទុំ ប្រើសំរាប់ :**

+ ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ១០.០០០៛ ដល់ ៧០.០០០៛

**- ប័ណ្ណពណ៌ខៀវខ្ចី ប្រើសំរាប់ :**

+ ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ១០០.០០០៛ ដល់ ៥០០.០០០៛

**- ប័ណ្ណពណ៌បៃតង ប្រើសំរាប់ :**

+ ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ៦០០.០០០៛ ដល់ ១.២០០.០០០៛

**ប្រការ៩.-** ដោយឡែក សំរាប់ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះ ចំពោះរថយន្តដឹកទំនិញ និង រ៉ឺម៉ក-សណ្ដោង ការកំណត់ចំនួនប្រាក់ពន្ធត្រូវផ្អែកតាមទម្ងន់សរុបដែលរួមមានទម្ងន់រថយន្តទទេ និងទម្ងន់ផ្ទុក (ទំនិញ-មនុស្ស)។

- ចំពោះរថយន្តដែលបំប្លែងមកពីគោយន្ត ត្រូវកំណត់ជារថយន្តដឹកទំនិញដល់ ៣ តោន និងត្រូវបង់ ១៥០.០០០៛ ។
- រីឯរថយន្តដឹកទំនិញធុនធ្ងន់ដែលមានភ្លៅ ៣ កង់ ១០ ប្រាក់ពន្ធត្រូវបង់ ៧៥០.០០០៛ (ឆកោណពណ៌ផ្កាឈូក) ។
- រថយន្តដឹកទំនិញដែលមានភ្លៅ ៣ កង់ ៦ ប្រាក់ពន្ធត្រូវបង់ ៤៥០.០០០៛ (ឆកោណពណ៌ទឹកប៊ិច)។
- រ៉ឺម៉កសណ្ដោងដែលមានភ្លៅ ២ កង់ ៨ ប្រាក់ពន្ធត្រូវបង់ ៤៥០.០០០៛ (ឆកោណពណ៌ទឹកប៊ិច) ។
- និងរ៉ឺម៉កសណ្ដោងដែលមានភ្លៅ ២ កង់ ៤ ប្រាក់ពន្ធត្រូវបង់ ២៥០.០០០៛ (ឆកោណពណ៌ស្វាយ)។

**ប្រការ១០.-** យានយន្តគ្រប់ប្រភេទដែលមានប័ណ្ណសំគាល់យានយន្ត ប៉ុន្តែមិនបានបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះ គ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៤ ហើយបានលក់ទៅឱ្យអ្នកផ្សេង ករណីនេះត្រូវកំណត់ឱ្យបង់ពន្ធសំរាប់ឆ្នាំ ២០០៤ និងបង់ប្រាក់ពិន័យតាមច្បាប់ ទើបអនុញ្ញាតឱ្យបង់ពន្ធសំរាប់ឆ្នាំ ២០០៥ ។

**ប្រការ១១.-** ចាប់ពីថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៥ នេះតទៅ អង្គភាពពន្ធដារនឹងធ្វើការត្រួតពិនិត្យជាកពិន័យចំនួនមួយដងស្មើប្រាក់ពន្ធ បន្ថែមលើប្រាក់ពន្ធដែលត្រូវបង់ចំពោះមធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំងឡាយណាដែលមិនបានមកបង់ពន្ធសំរាប់ឆ្នាំ ២០០៥ ដូចបានកំណត់ក្នុងប្រការ ១ ខាងលើ ។

ប៉ុន្តែចំពោះមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ដែលទើបដាក់ឱ្យធ្វើចរាចរនៅក្រោយថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០០៥ ត្រូវមានវិក្កយបត្របញ្ជាក់ ឬឯកសារផ្សេងៗចេញដោយអ្នកលក់ភ្ជាប់ជាមួយលិខិតប្រកាសសុំបង់ពន្ធ ។ បើពុំមកប្រកាសសុំបង់ពន្ធក្នុងរយៈពេល១ខែ គិតពីថ្ងៃដែលដាក់ឱ្យធ្វើចរាចរត្រូវពិន័យចំនួនមួយដងស្មើប្រាក់ពន្ធ បន្ថែមលើប្រាក់ពន្ធដែលត្រូវបង់សំរាប់ឆ្នាំ ២០០៥ នេះ ។

ការត្រួតពិនិត្យនឹងត្រូវអនុវត្តនៅតាមទីចំណតនៃមធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំងឡាយក្នុងភូមិ ឃុំ សង្កាត់.... និង ទីចំណតនានា ។

**ប្រការ១២.-** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៥

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាប"
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជ្រាបជាពត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- គ្រប់សាខាពន្ធដារខេត្ត-ក្រុង "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..៣១៣..សហវ...៣៥

## តារាងឧបសម្ព័ន្ធស្តីពីប្រាក់ពន្ធត្រូវកំណត់
## ចំពោះមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ

( តារាងឧបសម្ព័ន្ធទី I )

ភ្ជាប់ជាមួយប្រកាសលេខ....ប្រក.សហវ.ពជ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ឯកតា: រៀល**

| ប្រភេទមធ្យោបាយដឹកជញ្ជូន និង យានជំនិះ | កំរិតប្រាក់ពន្ធសំរាប់ ១ ឆ្នាំក្នុងមួយគ្រឿង | |
|---|---|---|
| - រថយន្តដឹកទំនិញមានទម្ងន់សរុប [ទម្ងន់រថយន្តទទេនិងទម្ងន់ផ្ទុក (ទំនិញនិងមនុស្ស)] : | | |
| + ដល់ ៣ តោន | ១៥០ ០០០ | |
| + លើសពី ៣ តោន ដល់ ១០ តោន | ២៥០ ០០០ | |
| + លើសពី ១០ តោន ដល់ ២០ តោន | ៤៥០ ០០០ | |
| + លើសពី ២០ តោន | ៧៥០ ០០០ | |
| - រ៉ឺម៉កសណ្តោងដែលមានទម្ងន់សរុប (រ៉ឺម៉កនិងទំនិញ) : | | |
| + ដល់ ១០ តោន | ២៥០ ០០០ | |
| + លើសពី ១០ តោន ដល់ ២០ តោន | ៤៥០ ០០០ | |
| + លើសពី ២០ តោន | ៧៥០ ០០០ | |
| - រថយន្តដឹកអ្នកដំណើរធុនធំ មានកៅអីលើសពី ២៥ កៅអី | ២៥០ ០០០ | |
| - រថយន្តដឹកអ្នកដំណើរធុនមធ្យម មានកៅអីពី ១៦កៅអី ដល់ ២៥ កៅអី | ២០០ ០០០ | |
| - រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥កៅអី | ១៥០ ០០០ | |
| - រថយន្តទេសចរណ៍ គ្រប់ប្រភេទ | គិតពីឆ្នាំផលិត | |
| | ដល់ ៥ ឆ្នាំ | លើសពី ៥ ឆ្នាំ |
| + កម្លាំងដល់ ៩ សេស | ១០០ ០០០ | ៨០ ០០០ |
| + កម្លាំងលើសពី ៩ សេស ដល់ ១២ សេស | ១៥០ ០០០ | ១០០ ០០០ |
| + កម្លាំងលើសពី ១២ សេស ដល់ ១៧ សេស | ២៥០ ០០០ | ១៨០ ០០០ |
| + កម្លាំងលើសពី ១៧ សេស ដល់ ២៤ សេស | ៨០០ ០០០ | ៦០០ ០០០ |

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

| | |
|---|---|
| + កម្លាំងលើសពី ២៤ សេស ឡើងទៅ | ១ 000 000 |
| - ត្រាក់ទ័រកម្លាំង ៨២ សេស និង គ្រឿងចក្រប្រហាក់ប្រហែល | ៥0 000 |
| - ត្រាក់ទ័រកម្លាំង ៦៥ សេស និង គ្រឿងចក្រប្រហាក់ប្រហែល | ៤0 000 |
| - ត្រាក់ទ័រកម្លាំង ៣៥ សេស និង គ្រឿងចក្រប្រហាក់ប្រហែល | ៣0 000 |
| **ប្រភេទមធ្យោបាយដឹកជញ្ជូន និង យានជំនិះ** | **អត្រាប្រាក់ពន្ធសំរាប់ ១ ឆ្នាំក្នុងមួយគ្រឿង** |
| - ទោចក្រយានយន្តទំហំពិសស្តុងដល់ ៧០ ស.ម³ | ៣ 000 |
| - ទោចក្រយានយន្តទំហំពិសស្តុងលើសពី ៧០ ស.ម³ ដល់ ១២៥ ស.ម³ | ៤ ៥00 |
| - ទោចក្រយានយន្តទំហំពិសស្តុងលើសពី ១២៥ ស.ម³ ឡើងទៅ | ៧ ៥00 |
| - ត្រីចក្រយានយន្តដឹកទំនិញ ឬអ្នកដំណើរ | ១៥ 000 |
| **<u>ជលយាន ឬជលយានយន្តផ្លូវទន្លេ</u> :** | |
| - ជលយានដឹកទំនិញ : | |
| + ដល់ ៣ តោន | ៥0 000 |
| + លើសពី ៣ តោន ដល់ ១០ តោន | ១00 000 |
| + លើសពី ១០ តោន ដល់ ២០ តោន | ២00 000 |
| +លើសពី ២០ តោន | ៣00 000 |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយដល់ ២០ ម៉ែត្រ | ១00 000 |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយលើសពី ២០ ម៉ែត្រ ដល់ ៣០ ម៉ែត្រ | ២00 000 |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយលើសពី ៣០ ម៉ែត្រ ឡើងទៅ | ៣00 000 |
| - កប៉ាល់សណ្តោងមានកំលាំងដល់ ៥០ សេស | ២0 000 |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ៥០ សេស ដល់ ១០០ សេស | ៣0 000 |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ១០០ សេស ដល់ ១៥០ សេស | ៥0 000 |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ១៥០ សេស ដល់ ២០០ សេស | ៦0 000 |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ២០០ សេស ដល់ ២៥០ សេស | ១៨0 000 |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ២៥០ សេស ឡើងទៅ | ៣00 000 |
| - កាណូតនេសាទមានកំលាំងដល់ ៥០ សេស | ១0 000 |
| - កាណូតនេសាទមានកំលាំងលើសពី ៥០ សេស ដល់ ១០០ សេស | ២0 000 |
| - កាណូតនេសាទមានកំលាំងលើសពី ១០០ សេស ដល់ ១៥០ សេស | ៣0 000 |
| - ទូកម៉ាស៊ីនចំហៀង " ជើងបង្កង " | ១0 000 |
| - អូប័រមានកំលាំងដល់ ២៥ សេស | ១៥0 000 |
| - អូប័រមានកំលាំងលើសពី ២៥ សេស ដល់ ៤០ សេស | ២00 000 |
| - អូប័រមានកំលាំងលើសពី ៤០ សេស ដល់ ៨០ សេស | ៣00 000 |
| - អូប័រមានកំលាំងលើសពី ៨០ សេស ដល់ ២០០ សេស | ៤00 000 |

| | |
|---|---|
| - អូប័រមានកំលាំងលើសពី ២០០ សេស ឡើងទៅ | ៥០០ ០០០ |
| <u>ជលយាន ឬជលយានយន្តផ្លូវសមុទ្រ</u> : | |
| - ទូកដឹកអ្នកដំណើរបណ្តោយដល់ ២០ ម៉ែត្រ | ១០០ ០០០ |
| - ទូកដឹកអ្នកដំណើរបណ្តោយពី ២១ ម៉ែត្រ ដល់ ៣០ ម៉ែត្រ | ១៥០ ០០០ |
| - ទូកដឹកទំនិញដល់ ១០០ តោន | ២០០ ០០០ |
| - ទូកនេសាទដែលមានកំលាំងសេសដល់ ៩ សេស | ១០ ០០០ |
| - ទូកនេសាទដែលមានកំលាំងសេសពី ១០ សេស ដល់ ២០ សេស | ១៥ ០០០ |
| - ទូកនេសាទដែលមានកំលាំងសេសពី ២១ សេស ដល់ ៤០ សេស | ២៥ ០០០ |
| - ទូកនេសាទដែលមានកំលាំងសេសពី ៤១ សេស ដល់ ៨០ សេស | ៥០ ០០០ |
| **ប្រភេទមធ្យោបាយដឹកជញ្ជូន និង យានជំនិះ** | **អាករត្រាក់ពន្ធសំរាប់ ១ ឆ្នាំក្នុងមួយគ្រឿង** |
| - ទូកនេសាទដែលមានកំលាំងសេសពី ៨១ សេស ដល់ ១៥០ សេស | ៧០ ០០០ |
| - ទូកនេសាទដែលមានកំលាំងសេសពី ១៥១ សេស ឡើងទៅ | ១០០ ០០០ |
| - ទូកនេសាទម៉ាស៊ីនចំហៀង (ជើងបង្កង) ដល់ ១២ សេស | ១០ ០០០ |
| - ទូកនេសាទម៉ាស៊ីនចំហៀង (ជើងបង្កង) ពី ១៣ សេស ដល់ ៥០ សេស | ២០ ០០០ |
| - ទូកនេសាទម៉ាស៊ីនចំហៀង (ជើងបង្កង) ពី ៥១ សេស ឡើងទៅ | ៥០ ០០០ |
| - កប៉ាល់ដឹកទំនិញដែលផ្ទុកបានដល់ ១.០០០ តោន | ៣០០ ០០០ |
| - កប៉ាល់ដឹកទំនិញផ្ទុកបានលើសពី ១.០០០ តោន ដល់ ២.០០០ តោន | ៧៥០ ០០០ |
| - កប៉ាល់ដឹកទំនិញផ្ទុកបានលើសពី ២.០០០ តោន ឡើងទៅ | ១ ២០០ ០០០ |
| - កប៉ាល់នេសាទមានកំលាំងដល់ ១៥០ សេស | ៣០០ ០០០ |
| - កប៉ាល់នេសាទមានកំលាំងលើសពី ១៥០ សេស ដល់ ២៥០ សេស | ៤០០ ០០០ |
| - កប៉ាល់នេសាទមានកំលាំងលើសពី ២៥០ សេស ដល់ ៥០០ សេស | ៦០០ ០០០ |
| - កប៉ាល់នេសាទមានកំលាំងលើសពី ៥០០ សេស ឡើងទៅ | ១ ២០០ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងដល់ ២៥០ សេស | ២០០ ០០០ |
| - កប៉ាលសណ្តោងមានកំលាំងលើសពី ២៥០ សេស ដល់ ៥០០ សេស | ៤០០ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ៥០០ សេស ឡើងទៅ | ៦០០ ០០០ |

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០០៥

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៣១៣០... សហវ.ទ.៣៥

# ឧបសម្ព័ន្ធកំណត់កំលាំងសេះរបស់រថយន្តទេសចរណ៍

(តារាងឧបសម្ព័ន្ធទី II)

ភ្ជាប់ជាមួយប្រកាសលេខ ៤៨៥០... ប្រក.សហវ.ពដ ចុះថ្ងៃទី ០៣. ខែ មិថុនា. ឆ្នាំ២០០៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

| ល.រ | រថយន្តទេសចរណ៍ដែលប្រើប្រាស់ ថាមពលសាំង ឬ មាសូត | ចំនួន CC "វ៉ូលូម" | កំលាំងគិតជាសេះ | ប្រាក់ពន្ធត្រូវបង់ | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | គិតពីឆ្នាំផលិត ដល់ ៥ឆ្នាំ | គិតពីឆ្នាំផលិត លើសពី ៥ឆ្នាំ | |
| ១ | រថយន្តទេសចរណ៍ | ដល់ ១ ៥០០ CC | ដល់ ៩ សេស | ១០០ ០០០ | ៨០ ០០០ | និយមហៅ ១.៥ |
| ២ | រថយន្តទេសចរណ៍ | លើសពី ១ ៥០០ CC ដល់ ២ ០០០ CC | លើសពី ៩ សេស ដល់ ១២ សេស | ១៥០ ០០០ | ១០០ ០០០ | និយមហៅ ១.៦ ដល់ ២ |
| ៣ | រថយន្តទេសចរណ៍ | លើសពី ២ ០០០ CC ដល់ ២ ៨០០ CC | លើសពី ១២ សេស ដល់ ១៧ សេស | ២៥០ ០០០ | ១៨០ ០០០ | និយមហៅ ២.២ ដល់ ២.៩ |
| ៤ | រថយន្តទេសចរណ៍ | លើសពី ២ ៨០០ CC ដល់ ៤ ០០០ CC | លើសពី ១៧ សេស ដល់ ២៤ សេស | ៨០០ ០០០ | ៦០០ ០០០ | និយមហៅ ៣ ដល់ ៤ |
| ៥ | រថយន្តទេសចរណ៍ | លើសពី ៤ ០០០ CC ឡើងទៅ | លើសពី ២៤ សេស ឡើងទៅ | ១ ០០០ ០០០ | | និយមហៅ លើសពី ៤ |

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០០៥

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ព្រះរាជាណាចក្រ កម្ពុជា

*Kingdom Of Cambodia*

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

